# ព្រឹទ្ធសភា

# SENATE MAGAZINE

## ទស្សនាវដ្ដីខែវិច្ឆិកា









លេខ ៣០១ ឆ្នាំទី២៥ ព.ស.២៥៦៩ គ.ស.២០២៥
Issue 301 Volume 25 BC 2569 BE 2025

# មាតិកា







## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា ( ១-១៤ )


- សម្តេចតេជោ **ហ៊ុន សែន** ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាដើម្បីសម្រេចលើរបៀបវារៈចំនួន២ ............................ ១
- ក្នុងនាមជាសមាជិកអាស៊ាននិងអង្គការសហប្រជាជាតិ កម្ពុជាបានចូលរួមចំណែកក្នុងការជំរុញភាពបៃតងនៅក្នុងតំបន់ក៏ដូចជាពិភពលោក.... ២
- សម្តេចតេជោ **ហ៊ុន សែន** ជំរុញឱ្យអ្នកវិនិយោគជប៉ុន ពង្រីកសក្តានុពលលើការវិនិយោគនៅកម្ពុជា ........................................ ៣
- សម្តេចតេជោ **ហ៊ុន សែន** អនុញ្ញាតឱ្យឯកឧត្តមឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋអូទ្រីសប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា ... ៤
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុញ្ញាតឱ្យគណៈប្រតិភូគណៈកម្មាធិការទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច នៃសភាប្រឹក្សានយោបាយប្រជាជនចិន ចូលជួបសម្តែងការគួរសម ........................................................................................ ៥
- ឯកឧត្តម **អ៊ុច បូររិទ្ធ** ផ្តល់អនុសាសន៍៧ចំណុចក្នុងសិក្ខាសាលាសភា ស្តីពីការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦..................... ៧
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញជាអធិបតីក្នុងពិធីប្រកាសចូលកាន់តំណែងអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ................ ៩
- សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ..................................................................................១១


## សកម្មភាពគណៈកម្មការនានារបស់ព្រឹទ្ធសភា ( ១៥-៤៤ )


- ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** អញ្ជើញជាអធិបតីក្នុងពិធីបើកបវេសនកាល ឆ្នាំសិក្សា២០២៥-២០២៦ នៅវិទ្យាល័យ២៤កញ្ញា ................ ១៥
- គណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងនាំយកព្រះរាជអំណោយ ជូនវីរកងទ័ពជួរមុខ ប្រចាំទិសមុំបី ... ១៦
- គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខនិងនាំយកចង្ក្រានសន្សំសំចៃថាមពលចែកជូនប្រជាពលរដ្ឋក្នុងស្រុក ប្រាសាទសំបូរ និងនាំយកព្រះរាជអំណោយ គ្រឿងឧបភោគ បរិភោគ ជូនកងពលតូចអន្តរាគមន៍លេខ៩ និងគ្រួសារកងទ័ពជួរមុខប្រចាំទិសមុំបី... ១៨
- ប្រជាជនភៀសសឹកនៅភូមិព្រៃចាន់ និងភូមិជោគជ័យ ទទួលបានការពិនិត្យនិងព្យាបាលជំងឺដែលរៀបចំដោយក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី៤ ..........................................................................................២០
- ប្រជាពលរដ្ឋស្រុកស្រីសន្ធរ ស្រុកស្ទឹងត្រង់ និងស្រុកពញាក្រែកទទួលបានការពិនិត្យនិងព្យាបាលជំងឺដែលរៀបចំដោយក្រុមសមាជិក ព្រឹទ្ធសភាប្រចាំភូមិភាគទី២ .......................................................................................... ២២
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ សហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តប្រទេសបារាំង អញ្ជើញចុះពិនិត្យនិងព្យាបាលជំងឺទូទៅ ជូនប្រជាពលរដ្ឋនៅស្រុកស្អាង ..........................................................................................២៤
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមអភិវឌ្ឍន៍សុខុមាលភាពកម្ពុជា-បារាំង ចុះពិនិត្យនិងព្យាបាលជំងឺជូនប្រជាពលរដ្ឋរស់នៅស្រុកគិរីវង់ ដោយឥតគិតថ្លៃ ..........................................២៥
- ក្រុមសមាជិកាព្រឹទ្ធសភាអញ្ជើញចែកធុងចម្រោះទឹកស្អាតជូនដល់ប្រជាពលរដ្ឋរស់នៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង......................... ២៧
- សិក្ខាកាមកម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់នៃសាលាភូមិន្ទរដ្ឋបាល អញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា............២៩
- កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា.............................................................. ៣១
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ............................................................................ ៣៤
- ការទទួលពាក្យបណ្តឹង............................................................................................................ ៣៥
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨ ........................................................... ៣៦
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ ............................................................................... ៤៣


## សកម្មភាពអគ្គលេខាធិការដ្ឋាន ( ៤៥-៥៣ )


- ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាអញ្ជើញសំណេះសំណាលជាមួយនិវត្តជន និងមន្ត្រីរាជការរ៉យចំណាស់ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា...........................................................................................៤៥
- ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងកំណត់ទិសដៅការងារ ខែវិច្ឆិកា ឆ្នាំ២០២៥.............................................................................................៤៧
- ឯកឧត្តម **ឡាយ សំកុល** អញ្ជើញចូលរួមពិធីបើកវេទិកាកិច្ចសហប្រតិបត្តិការច្បាប់ចិន-អាស៊ាន លើកទី៧ នៅទីក្រុងធុងឈីង សាធារណរដ្ឋប្រជាមានិតចិន ...............................................................................................៤៩
- ឯកឧត្តម **ឡាយ សំកុល** អញ្ជើញជួបពិភាក្សាការងារជាមួយអគ្គលេខាធិការនៃមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន នៅទីក្រុងធុងឈីង សាធារណរដ្ឋប្រជាមានិតចិន ...............................................................................................៥០
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ .......................................................៥១



**អ្នកគ្រប់គ្រងទូទៅ**
ឯកឧត្តម ឡាយ សំកុល

**អ្នកសម្របសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**
ឯកឧត្តម ខេង សិទ្ធិគុណា
ឯកឧត្តម ជាម សុផលមករា
ឯកឧត្តម ជួន ណា
លោក ជួន សុខជី
លោក ទេព មករា
លោក កុក វ៉ៃ
លោក សុង សុខភារ័ត្ន

**អ្នកគ្រប់គ្រងផ្ទាល់**
លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**
ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**
លោក ជុំ ច័ន្ទរតនា
លោក ធុន គីមជី
លោកស្រី សុខ សុជាតា


### ក្របមុខ

*- សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី៣៣ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ។*

*- ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងពិធីប្រកាសចូលកាន់តំណែងអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។*

*- ឯកឧត្តមបណ្ឌិត **ឆន់ ខន្សៀនា** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយក្រុមប្រឹក្សាសង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ៕*

# សម្តេចតេជោ ហ៊ុន សែន ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសម្រេចលើរបៀបវារៈចំនួន២



*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា*

នាព្រឹកថ្ងៃចន្ទ ទី២៧ ខែតុលា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន២ មានដូចខាងក្រោម៖

**១-សំណើរបស់គណៈកម្មការពិសេសលើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។**

**២-ផ្សេងៗ។**

បន្ទាប់ពីបានពិនិត្យនិងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានសម្រេចបញ្ជូនសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ទៅរដ្ឋសភា ដើម្បីពិនិត្យនិងអនុម័តតាមការគួរ។





*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ក្នុងនាមជាសមាជិកអាស៊ាននិងអង្គការសហប្រជាជាតិ កម្ពុជាបាន ចូលរួមចំណែកក្នុងការជំរុញភាពបៃតងនៅក្នុងតំបន់ក៏ដូចជាពិភពលោក

នារសៀលថ្ងៃសុក្រ ទី៣១ ខែតុលា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យលោក Tan Sri Michael YEOH ប្រធានវិទ្យាស្ថានយុទ្ធសាស្ត្រ KSI ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។



*លោក Tan Sri Michael YEOH និងសម្តេចតេជោ ហ៊ុន សែន*

ក្នុងជំនួបនោះ **សម្តេចតេជោ** បានសម្តែងនូវការចាប់អារម្មណ៍ទាក់ទងនឹងតួនាទីរបស់ KSI ក្នុងការចូលរួមចំណែកនិងផ្តល់ជាយុទ្ធសាស្ត្រអភិវឌ្ឍក្នុងតំបន់ទាក់ទងនឹងបរិស្ថាន។ **សម្តេច**បានគូសបញ្ជាក់ថា ក្នុងនាមជាសមាជិកអាស៊ាន និងអង្គការសហប្រជាជាតិ កម្ពុជាបានចូលរួមចំណែកក្នុងការជំរុញភាពបៃតងនៅក្នុងតំបន់ក៏ដូចជាពិភពលោក។ **សម្តេច**បានរំលេចនិងចែករំលែកអំពីទស្សនវិស័យទាក់ទងនឹងការគ្រប់គ្រងប្រទេសកម្ពុជា ក៏ដូចជាចូលរួមចំណែកក្នុងវិស័យការពារបរិស្ថាននៅក្នុងប្រទេសកម្ពុជា តំបន់ និងសកលលោក។ **សម្តេច**បានលើកជាឧទាហរណ៍នាពេលកន្លងទៅក៏ដូចជាពេលបច្ចុប្បន្ននេះ កម្ពុជាបានចូលរួមចំណែកជាមួយពិភពលោក ដោយមិនគិតថាប្រទេសតូចឬប្រទេសធំនោះទេ សុទ្ធតែមានចំណែកទទួលខុសត្រូវក្នុងការការពារបរិស្ថាន ដោយធ្វើយ៉ាងណាកាត់បន្ថយបម្រែបម្រួលអាកាសធាតុរបស់ពិភពលោក។

បន្ថែមពីនេះ **សម្តេច**បានរំលេចអំពីស្ថានភាពនាពេលបច្ចុប្បន្នរបស់កម្ពុជាទាក់ទងនឹងការប្រើប្រាស់រថយន្តនៅរាជធានីភ្នំពេញ ដោយប្រជាពលរដ្ឋកម្ពុជាកំពុងតែមានចំណាប់អារម្មណ៍ការប្រើប្រាស់រថយន្តអគ្គិសនី ដែលនេះជាផ្នែកមួយក្នុងការគាំពារដល់បរិស្ថាន កាត់បន្ថយឧស្ម័នពុល និងរួមចំណែកជំរុញឱ្យមានភាពល្អប្រសើរដល់បរិស្ថាន និងកាត់បន្ថយបម្រែបម្រួលអាកាសធាតុ។ ទន្ទឹមគ្នានោះ **សម្តេចតេជោ** ក៏បានអបអរសាទរចំពោះការចូលរួមរបស់គណៈប្រតិភូនៅក្នុងកិច្ចប្រជុំកំពូលបៃតង និងចីរភាពសកលឆ្នាំ២០២៥ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

នៅក្នុងឱកាសនោះ **លោកប្រធានវិទ្យាស្ថាន**បានថ្លែងអំណរគុណចំពោះ**សម្តេចតេជោ** ដែលបានអនុញ្ញាតឱ្យរូបលោក និងគណៈប្រតិភូបានជួបសម្តែងការគួរសម។ **លោកប្រធានវិទ្យាស្ថាន**បានកោតសរសើរចំពោះភាពរីកចម្រើនរបស់កម្ពុជា តាំងពីការដឹកនាំរបស់**សម្តេចតេជោ** រហូតមកដល់ការដឹកនាំរបស់**សម្តេចធិបតី** ជានាយករដ្ឋមន្ត្រីនាពេលបច្ចុប្បន្ន។ លោកបានលើកឡើងថា កម្ពុជាបានចូលរួមចំណែកយ៉ាងសកម្មទាំងក្នុងតំបន់ និងនៅលើពិភពលោកក្នុងគោលដៅការពារបម្រែបម្រួលអាកាសធាតុ និងការជំរុញឱ្យមានភាពបៃតង។



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

**លោកប្រធានវិទ្យាស្ថាន**បានសម្តែងអរគុណចំពោះ**សម្តេចតេជោ** ដែលបានចែករំលែកនូវទស្សនាទានល្អៗសម្រាប់ក្រុមអ្នកស្រាវជ្រាវរបស់លោកយកទៅដាក់ក្នុងផែនការស្រាវជ្រាវនិងជាគំនិតយោបល់បន្ថែម ដើម្បីយកទៅបង្ហាញដល់វេទិកាសាធារណៈផ្សេងៗ។ ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរឱ្យគណៈប្រតិភូទាំងអស់ទទួលបានជោគជ័យក្នុងការបំពេញបេសកកម្មនៅព្រះរាជាណាចក្រកម្ពុជា៕

ប្រភព៖ Telegram Channel សម្តេចតេជោ
សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន

# សម្តេចតេជោ ហ៊ុន សែន ជំរុញឱ្យអ្នកវិនិយោគជប៉ុន ពង្រីកសក្តានុពល លើការវិនិយោគនៅកម្ពុជា

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញនូវការពេញចិត្តនិងជំរុញឱ្យអ្នកវិនិយោគជប៉ុន ចាប់អារម្មណ៍ និងពង្រីកសក្តានុពលលើវិស័យនានា ឱ្យមានការកើនឡើងថែមទៀត។ ការលើកឡើងនេះ ក្នុងឱកាសដែល **សម្តេចតេជោ** អនុញ្ញាតឱ្យ ឯកឧត្តម TAKAHASHI Fumiaki ប្រធានសមាគមជប៉ុន-កម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមាន៧មករា នាព្រឹកថ្ងៃចន្ទ ទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥។



*សម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម TAKAHASHI Fumiaki*

**សម្តេចតេជោ** បានសម្តែងក្តីរីករាយដោយបានជួបជាមួយប្រតិភូនៃសមាគមជប៉ុន-កម្ពុជាសាជាថ្មី និងពេញចិត្តចំពោះវឌ្ឍនភាពរបស់សមាគមជប៉ុន-កម្ពុជា ដែលបានចូលរួមចំណែក និងខិតខំប្រឹងប្រែងនៅក្នុងការផ្សារភ្ជាប់ទំនាក់ទំនងប្រទេសទាំងពីរ ព្រមទាំងការទាក់ទាញអ្នកវិនិយោគជប៉ុនឱ្យមកវិនិយោគនៅប្រទេសកម្ពុជា ជាពិសេសការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបន្ថែមទៀតដល់ប្រជាជនកម្ពុជា ជាពិសេសយុវជនកម្ពុជា។ **សម្តេច**បានលើកឡើងថាជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាជំនាញនៃតម្រូវការទាំងក្នុងបរិបទប្រទេសកម្ពុជា ក៏ដូចជាបរិបទនៅប្រទេសជប៉ុន ហើយក៏ជាចំណែកមួយក្នុងការជំរុញផ្នែកសេដ្ឋកិច្ចដ៏សំខាន់ផងដែរ។

នៅក្នុងជំនួបនោះ **ឯកឧត្តមប្រធានសមាគម** បានលើកឡើងថា ប្រទេសកម្ពុជា គឺទទួលបាននូវការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់អ្នកវិនិយោគជប៉ុន ក្នុងការមកវិនិយោគលើវិស័យនានា។ វត្តមានគណៈប្រតិភូដែលមកកម្ពុជានៅពេលនេះ គឺមាន៣៦ក្រុមហ៊ុន ដែលជាក្រុមហ៊ុនជប៉ុន។ ក្រុមហ៊ុនទាំងនោះ ភាគច្រើនជាក្រុមហ៊ុនវិនិយោគលើវិស័យបច្ចេកវិទ្យាបណ្តុះបណ្តាលវិជ្ជាជីវៈ និងកសិ-ឧស្សាហកម្ម។

**ឯកឧត្តមប្រធានសមាគម** បានថ្លែងអំណរគុណចំពោះការគាំទ្ររបស់រាជរដ្ឋាភិបាលកម្ពុជាកាលពីពេលកន្លងទៅ ជាពិសេសតាំងពីពេល**សម្តេចតេជោ** នៅជានាយករដ្ឋមន្ត្រី ហើយមកដល់ពេលនេះ **សម្តេចតេជោ** ជាប្រធានព្រឹទ្ធសភា ក៏**សម្តេច**នៅតែបន្តគាំទ្រអ្នកវិនិយោគជប៉ុន ដែលការនេះ គឺជាកម្លាំងចិត្តដ៏សំខាន់ក្នុងការផ្តល់នូវទំនុកចិត្តដល់អ្នកវិនិយោគជប៉ុន មកវិនិយោគនៅកម្ពុជាបន្ថែមទៀត។

**សម្តេចតេជោ** បានលើកឡើងថា ផ្នែកកសិ-ឧស្សាហកម្ម គឺជាចំណុចស្នូលមួយរបស់រាជរដ្ឋាភិបាលកម្ពុជា តាំងពីដើមរៀងមក រហូតមកដល់រាជរដ្ឋាភិបាលថ្មី ដឹកនាំដោយសម្តេចធិបតី **ហ៊ុន ម៉ាណែត** ក៏ចាត់ទុកកសិ-ឧស្សាហកម្មគឺជារឿងចាំបាច់និងអាទិភាព។ ពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យា បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាកំពុងតែផ្តោតការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យា ហើយកម្ពុជាក៏កំពុងមានតម្រូវការខ្លាំងក្នុងផ្នែកនេះ។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរគណៈប្រតិភូទាំងអស់ ឱ្យបំពេញបេសកកម្មនៅកម្ពុជាប្រកបដោយភាពជោគជ័យ៕





*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារ*

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន

# សម្តេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យឯកឧត្តមឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋអូទ្រីសប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា

នាព្រឹកថ្ងៃអង្គារ ទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម Wilhelm Maximilian Donko ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋអូទ្រីស ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងជម្រាបលា នៅវិមានព្រឹទ្ធសភា។ នៅក្នុងជំនួបនោះ **សម្តេចតេជោ** បានវាយតម្លៃខ្ពស់ចំពោះតួនាទីរបស់**ឯកឧត្តមឯកអគ្គរដ្ឋទូត** ក្នុងការចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍទំនាក់ទំនងរវាងកម្ពុជានិងអូទ្រីស។



*ឯកឧត្តម Wilhelm Maximilian Donko និងសម្តេចតេជោ ហ៊ុន សែន*

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានសម្តែងនូវការអរគុណចំពោះសម្តេចតេជោ **ហ៊ុន សែន** ដែលបានអនុញ្ញាតឱ្យចូលជួបសម្តែងការគួរសម និងបានបញ្ជាក់អំពីទំនាក់ទំនងដ៏ល្អរវាងកម្ពុជានិងអូទ្រីស នាពេលកន្លងទៅ ហើយបច្ចុប្បន្នកំពុងតែត្រូវបានពង្រីកបន្ថែមទៀត។ ជាមួយគ្នានោះ ឯកឧត្តមក៏បានរំលេចអំពី ការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ដែលមានការរីកចម្រើនគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ មានអគារខ្ពស់ៗជាច្រើនបានរីកដុះដាលជាបន្តបន្ទាប់។

ក្នុងក្របខ័ណ្ឌទំនាក់ទំនងទ្វេភាគី **ឯកឧត្តមឯកអគ្គរដ្ឋទូត**បានបញ្ជាក់ថា នាពេលកន្លងទៅ អូទ្រីសបានចូលរួមចំណែកក្នុងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា រួមមាន៖ វិស័យដោះមីននិងការជួយជ្រោមជ្រែងដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ទន្ទឹមនឹងនេះ ឯកឧត្តមសង្ឃឹមថា ទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ នឹងមានការកើនឡើងដោយសារអ្នកវិនិយោគរបស់អូទ្រីស នឹងមកទស្សនកិច្ចស្វែងរកឱកាសវិនិយោគនៅកម្ពុជា។

**សម្តេចតេជោ** បានសម្តែងនូវការអរគុណចំពោះប្រទេសអូទ្រីស ដែលបានចូលរួមចំណែកក្នុងវិស័យដោះមីន និងជួយជ្រោមជ្រែងដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រមទាំងសហប្រតិបត្តិការដ៏ល្អមួយចំនួនទៀត ដែលកម្ពុជានិងអូទ្រីសបានធ្វើជាមួយគ្នា។ **សម្តេច** បានឯកភាពចំពោះការលើកឡើងរបស់**ឯកឧត្តមឯកអគ្គរដ្ឋទូត** ដែលធ្វើយ៉ាងណាជំរុញវិស័យពាណិជ្ជកម្មរវាងកម្ពុជានិងអូទ្រីស ឱ្យមានការកើនឡើង។ **សម្តេចតេជោ**បានបញ្ជាក់ថា បច្ចុប្បន្នស្ថានភាពទំនាក់ទំនងនយោបាយការបរទេសរវាងប្រទេសទាំងពីរមានភាពរីកចម្រើនជាបន្តបន្ទាប់ដូច្នេះទាមទារបន្ថែមទៀតនូវការពង្រីកទំហំពាណិជ្ជកម្ម សេដ្ឋកិច្ច និងវិនិយោគ ឱ្យមានការរីកចម្រើនទៅជាមួយគ្នា។

ក្នុងក្របខ័ណ្ឌទ្វេភាគី **សម្តេចតេជោ** ចង់ឃើញក្រសួងការបរទេសនៃប្រទេសទាំងពីរ ស្វែងរកយន្តការបង្កើនសហប្រតិបត្តិការជាមួយគ្នាជាបន្តបន្ទាប់ទៀត។ **សម្តេច** បានជូនពរ**ឯកឧត្តមឯកអគ្គរដ្ឋទូត** និងប្រតិភូ ទទួលបានជោគជ័យក្នុងបេសកកម្មការងារជាបន្តបន្ទាប់ទៀត៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# ឯកឧត្តម អ៊ុច បូរិទ្ធ អនុញ្ញាតឱ្យគណៈប្រតិភូគណៈកម្មាធិការទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច នៃសភាប្រឹក្សានយោបាយប្រជាជនចិន ចូលជួបសម្តែងការគួរសម

នារសៀលថ្ងៃចន្ទ ទី៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ ព្រឹទ្ធសភា បានអនុញ្ញាតឱ្យឯកឧត្តម **វ៉ាង គួរសឹង** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាប្រធានគណៈ-កម្មាធិការទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច នៃសភាប្រឹក្សានយោបាយប្រជាជនចិននិងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។



*ឯកឧត្តម វ៉ាង គួរសឹង និងឯកឧត្តម អ៊ុច បូរិទ្ធ*

ក្នុងឱកាសនោះ **ឯកឧត្តមអនុប្រធានទី១** បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូសភាប្រឹក្សានយោបាយប្រជាជនចិន ក្នុងដំណើរទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី៣-៥ ខែវិច្ឆិកា ឆ្នាំ២០២៥។ ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តមបានជម្រាបជូននូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ** ប្រធានព្រឹទ្ធសភា ជូនចំពោះ ឯកឧត្តម **វ៉ាង ហ៊ូនីង** ប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន ក៏ដូចជាការផ្តាំផ្ញើសួរសុខទុក្ខរបស់ឯកឧត្តមជូនចំពោះ ឯកឧត្តម **ហឺ ពីង** ប្រធានក្រុមមិត្តភាពសភាប្រឹក្សានយោបាយប្រជាជនចិន និងព្រឹទ្ធសភាកម្ពុជា។

ជាមួយនឹងការគូសបញ្ជាក់ពីសារៈសំខាន់នៃដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ ដែលជាផ្នែកមួយនៃការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងអង្គនីតិប្បញ្ញត្តិទាំងពីរ (កម្ពុជា-ចិន) **ឯកឧត្តមអនុប្រធានទី១**បានផ្តោតការយកចិត្តទុកដាក់លើការរៀបចំឱ្យមានការជួបប្រាស្រ័យគ្នាឱ្យបានទៀងទាត់ ដែលនឹងផ្តល់ឱកាសឱ្យអង្គនីតិប្បញ្ញត្តិទាំងពីរអាចធ្វើការផ្លាស់ប្តូរបទពិសោធ និងមតិយោបល់គ្នាជុំវិញបញ្ហាក្នុងតំបន់ អន្តរជាតិ ក៏ដូចជាបញ្ហាប្រឈមផ្សេងៗទៀត។

**ឯកឧត្តមអនុប្រធានទី១**បានរំឭកពីការប្រកាន់ជំហរឥតងាករេរបស់រាជរដ្ឋាភិបាលចំពោះគោលនយោបាយចិនតែមួយ និងការគាំទ្រចំពោះការផ្តួចផ្តើមគំនិត «ផ្លូវមួយ ខ្សែក្រវាត់មួយ» ក៏ដូចជាគំនិតផ្តួចផ្តើមផ្សេងៗទៀតរបស់លោកប្រធានាធិបតី **ស៊ី ជិនពីង** ជាពិសេស «គំនិតផ្តួចផ្តើមអភិវឌ្ឍន៍សកល» ដែលបានរួមចំណែកដ៏សំខាន់ដល់ការខិតខំ





*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

ប្រឹងប្រែងរបស់កម្ពុជាក្នុងការសម្រេចបាននូវ «គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព» សមស្របតាម «យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទីមួយ» របស់រាជរដ្ឋាភិបាល។ ជាមួយគ្នានោះ ឯកឧត្តមបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះជំនួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លារបស់ប្រជាជន និងរដ្ឋាភិបាលចិន ចំពោះការអភិវឌ្ឍប្រទេសជាតិ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលទស្សនកិច្ចរបស់លោកប្រធានាធិបតី **ស៊ី ជិនពីង** នៅកម្ពុជាកាលពីខែមេសា និងទស្សនកិច្ចរបស់



*ទិដ្ឋភាពក្នុងជំនួបសម្ដែងការគួរសម*

**សម្ដេចធិបតីនាយករដ្ឋមន្ត្រី** អញ្ជើញចូលរួមកិច្ចប្រជុំកំពូលអង្គការសហប្រតិបត្តិការសៀងហៃ (SCO) ឆ្នាំ២០២៥ កាលពីខែសីហាកន្លងទៅ ដែលជាសក្ខីភាពបង្ហាញឱ្យឃើញពីការរីកចម្រើនដ៏រឹងមាំនៃចំណង «មិត្តភាពដែកថែប» កម្ពុជា-ចិន និង «ការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ក្នុងយុគសម័យថ្មី គ្រប់រដូវកាល» ដើម្បីជាគុណប្រយោជន៍រួមរបស់ប្រទេសទាំងពីរ។

ជាការឆ្លើយតប ឯកឧត្តម **វ៉ាង គួរសឹង** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបដិសណ្ឋារកិច្ចដ៏កក់ក្ដៅ និងបង្ហាញពីក្ដីសោមនស្សរីករាយដែលបានអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជា ព្រមទាំងគូសបញ្ជាក់ពីសារៈសំខាន់នៃដំណើរទស្សនកិច្ចដែលមានទិសដៅលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ធ្វើឱ្យកាន់តែស៊ីជម្រៅលើកិច្ចសហប្រតិបត្តិការត្បូងពេជ្រ និងជំរុញការកសាងសហគមន៍កម្ពុជា-ចិន ជាមួយនឹងអនាគតរួមគ្នាក្នុងយុគសម័យថ្មី ប្រកបដោយគុណភាពខ្ពស់ កម្រិតខ្ពស់ និងស្តង់ដាខ្ពស់។ នៅក្នុងទិសដៅនេះ ឯកឧត្តមបានបញ្ជាក់ថាគណៈប្រតិភូនឹងអញ្ជើញទៅបំពេញទស្សនកិច្ចនៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ដើម្បីស្វែងរកកាលានុវត្តភាពថ្មីៗសម្រាប់ការវិនិយោគ ដោយបានសន្យាថា នឹងកៀរគរអ្នកវិនិយោគពីប្រទេសចិនឱ្យមកវិនិយោគនៅក្នុងប្រទេសកម្ពុជា និយាយជារួម និងជាពិសេសតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ សំដៅពន្លឿនការវិនិយោគ និងការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។ ឯកឧត្តម **វ៉ាង គួរសឹង** ក៏បាននាំការផ្ដាំផ្ញើសួរសុខទុក្ខ និងក្ដីនឹករលឹករបស់ឯកឧត្តម **វ៉ាង ហ៊ូនីង** ប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន ជូនចំពោះ **សម្ដេចតេជោ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងបានសម្ដែងនូវជំនឿជឿជាក់ថា ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាវាងអង្គនិតីប្បញ្ញត្តិទាំងពីរ( កម្ពុជា-ចិន ) កាន់តែត្រូវបានពង្រឹងពង្រីកថែមទៀត ដើម្បីជាផលប្រយោជន៍ដល់ប្រជាជាតិទាំងពីរ និងដើម្បីសន្តិភាព ស្ថិរភាព និងកិច្ចអភិវឌ្ឍ៕



*ឯកឧត្តម អ៊ុច បូរិទ្ធ ថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូគណៈកម្មាធិការទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច នៃសភាប្រឹក្សានយោបាយប្រជាជនចិន*

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម អ៊ុច បូរិទ្ធ ផ្តល់អនុសាសន៍៧ចំណុចក្នុងសិក្ខាសាលាសភា ស្តីពីការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦




*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីបិទសិក្ខាសាលា*

ក្នុងនាមស្ថាប័ននីតិប្បញ្ញត្តិ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានចូលរួមផ្តល់ជាអនុសាសន៍ចំនួន៧ចំណុចដល់អង្គសិក្ខាសាលាសភាក្នុងនោះរួមមាន៖១-ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនៅតែជាមូលដ្ឋានគ្រឹះនៃទំនុកចិត្តរបស់វិនិយោគិននិងវឌ្ឍនភាពសង្គម ២-សារៈសំខាន់នៃការពង្រឹងភាពធន់នៃសារពើពន្ធ ជាពិសេសត្រូវផ្តោតទៅលើការបន្តកំណែទម្រង់ក្នុងការគ្រប់គ្រងពន្ធនិងគយ ៣-គុណភាពនិងតម្លាភាពក្នុងការវិនិយោគសាធារណៈ គឺមិនអាចខ្វះបាន ៤-បរិវត្តកម្មឌីជីថលនៅតែជាផ្នែកសំខាន់មួយនៃអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព ៥-ធនធានមនុស្ស គឺជាចំណុចស្នូលនៃកំណើនរយៈពេលវែងរបស់កម្ពុជា ៦-ក្របខ័ណ្ឌគ្រប់គ្រងហិរញ្ញវត្ថុនាពេលអនាគតរបស់យើងត្រូវតែរួមបញ្ចូលវិធានការដែលអនុញ្ញាតឱ្យប្រទេសកម្ពុជាទប់ទល់នឹងផលប៉ះពាល់ពីខាងក្រៅ រួមទាំងបញ្ហាប្រឈមអាកាសធាតុ ភាពចលាចលភូមិសាស្ត្រនយោបាយ និងការរំខានដល់បច្ចេកវិទ្យា ៧-ត្រូវយកចិត្តទុកដាក់លើថាមវន្តក្នុងតំបន់ដែលពេលខ្លះអាចមានឥទ្ធិពលលើបរិយាកាសផ្ទៃក្នុងរបស់កម្ពុជា។

**ឯកឧត្តមអនុប្រធានទី១** បានផ្តល់អនុសាសន៍យ៉ាងដូច្នេះ ក្នុងឱកាសដែលឯកឧត្តមអញ្ជើញជាអធិបតីក្នុងពិធីបិទសិក្ខាសាលាសភា ស្តីពី «ការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦» នៅវិមានរដ្ឋសភា នាព្រឹកថ្ងៃចន្ទ ទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥។

បន្ថែមពីនេះ **ឯកឧត្តមអនុប្រធានទី១** បានផ្តល់អនុសាសន៍បន្ថែមថា ការរៀបចំច្បាប់គ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០២៦




*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញមានប្រសាសន៍បិទអង្គសិក្ខាសាលាសភា*

គួរតែឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (SDGs) និងភាពបន្ទាន់នៃការជំរុញសកម្មភាពអាកាសធាតុ ព្រមទាំងសេចក្តីប្រាថ្នារយៈពេលវែងរបស់កម្ពុជា រួមទាំងចក្ខុវិស័យរបស់យើងក្នុងការចេញផុតពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចបំផុត ដើម្បីសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០។

ទន្ទឹមនឹងនេះ **ឯកឧត្តមអនុប្រធានទី១** បានសង្កត់ធ្ងន់ថា សិក្ខាសាលានេះ គឺជាវេទិកាមួយដ៏មានសារៈសំខាន់បំផុតសម្រាប់តួអង្គពាក់ព័ន្ធទាំងអស់ក្នុងការទទួលបាននូវព័ត៌មានសម្រាប់ធ្វើជាមូលដ្ឋានក្នុងការសិក្សា វិភាគ និងវាយតម្លៃបន្ថែមលើសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។

ក្នុងឱកាសនោះផងដែរ **ឯកឧត្តមអនុប្រធានទី១** បានគូសបញ្ជាក់ថា កម្ពុជាបានធ្វើដំណើរលើមាគ៌ាដ៏វែងឆ្ងាយពីជម្លោះ និងការបែកបាក់ មកកាន់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ។ ការផ្លាស់ប្តូរប្រទេសជាតិដ៏ស៊ីជម្រៅនេះអាចសម្រេចទៅបានតាមរយៈនយោបាយ «ឈ្នះ-ឈ្នះ» ជាប្រវត្តិសាស្ត្រនិងប្រកបដោយចក្ខុវិស័យវែងឆ្ងាយ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងអង់អាចរបស់ សម្តេចតេជោ **ហ៊ុន សែន** ដែលជាឯកស្ថាបនិក នៃការបង្រួបបង្រួមជាតិ និងសុខសន្តិភាពយូរអង្វែងសម្រាប់មាតុភូមិកម្ពុជា។ ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ កម្ពុជាសម្រេចបាននូវវឌ្ឍនភាពសង្គម-សេដ្ឋកិច្ចដ៏គួរឱ្យចាប់អារម្មណ៍ រួមមាន៖ កំណើនសេដ្ឋកិច្ចរឹងមាំ, ការកាត់បន្ថយភាពក្រីក្របានយ៉ាងច្រើនសន្ធឹកសន្ធាប់, សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងសកលកាន់តែស៊ីជម្រៅ។ វឌ្ឍនភាពនេះ មិនត្រឹមតែបានធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅ និងធានាបាននូវស្ថិរភាពសង្គមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានលើកកម្ពស់មុខមាត់របស់កម្ពុជានៅលើឆាកអន្តរជាតិផងដែរ។

**ឯកឧត្តមអនុប្រធានទី១** បានមានប្រសាសន៍បន្តថា ខណៈដែលកម្ពុជាកំពុងឈានទៅមុខក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយបញ្ញាញាណរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ នឹងបម្រើជាឧបករណ៍យុទ្ធសាស្ត្រ ដើម្បីធានាថា ស្ថាបត្យកម្មសារពើពន្ធរបស់យើងនឹងគាំទ្រដល់អាទិភាពជាតិសំខាន់ៗ រួមមាន៖ ការការពារអធិបតេយ្យជាតិ និងសន្តិភាព ការធានាស្ថិរភាពសង្គម-សេដ្ឋកិច្ច និងម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន ព្រមទាំងការបង្កើនសមត្ថភាពប្រកួតប្រជែងជាតិ។

**ឯកឧត្តមអនុប្រធានទី១** បានរំលេចបន្ថែមថា ទោះបីជារយៈពេល៣ឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពនិងសមិទ្ធផលសំខាន់ៗគួរជាទីមោទនៈយ៉ាងណាក្តី តែយើងក៏នៅមានបញ្ហាប្រឈមនានាជាច្រើន ដែលតម្រូវឱ្យយើងទាំងអស់គ្នាត្រូវតែខិតខំប្រឹងប្រែង សហការគ្នាឱ្យកាន់តែជិតស្និទ្ធ និងរឹងមាំបន្ថែមទៀត ដោយផ្អែកលើស្មារតីសាមគ្គីភាព ឯកភាពជាតិជាធ្លុងមួយ ដើម្បីឈានទៅដោះស្រាយបញ្ហាប្រឈមទាំងអស់នោះបាន។

នៅចុងបញ្ចប់ **ឯកឧត្តមអនុប្រធានទី១** បានថ្លែងអំណរគុណចំពោះគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា និងព្រឹទ្ធសភា ព្រមទាំងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានសហការរៀបចំសិក្ខាសាលាដ៏មានសារៈសំខាន់នេះឡើង ព្រមទាំងថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានសភាទាំងពីរ (ព្រឹទ្ធសភា និងរដ្ឋសភា) និងភាគីពាក់ព័ន្ធ ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងសិក្ខាសាលាសភានៅព្រឹកនោះ៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពថតរូបអនុស្សាវរីយ៍ក្នុងពិធីបិទអង្គសិក្ខាសាលា*

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីប្រកាសចូលកាន់តំណែង អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

នាព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសចូលកាន់តំណែងរបស់ ឯកឧត្តម **ឌី បញ្ញា** ជាអគ្គលេខាធិការរងព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំខុទ្ទកាល័យ ថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។



*ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា*

មានមតិសំណេះសំណាលនាឱកាសនោះ **ឯកឧត្តម អនុប្រធានទី១** បានរំលឹកថា ជាការចាប់ផ្តើមនៃទំព័រប្រវត្តិ-សាស្ត្រថ្មីសម្រាប់ព្រឹទ្ធសភានីតិកាលទី៥ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា, **សម្តេច**បានដាក់ចេញនូវអាទិភាពយុទ្ធសាស្ត្រពីរ ក្នុងចំណោមអាទិភាពទាំងឡាយរបស់ព្រឹទ្ធសភា គឺអាទិភាពចម្បងទី១៖ការលើកកម្ពស់ការទូតសភាដើម្បីចូលរួមបំពេញបន្ថែមលើសកម្មភាពដឹកនាំដោយរាជរដ្ឋាភិបាល និងរដ្ឋសភាក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាព សម្រាប់តំបន់ និងសកលលោក និងអាទិភាពចម្បងទី២៖ការរួមប្រាស្រ័យកាន់តែជិតស្និទ្ធជាមួយអង្គបោះឆ្នោត ជាពិសេសជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលតំណាងឱ្យប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីបន្តរួមចំណែកដល់ដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាសាធារណៈ និងការអភិវឌ្ឍប្រទេសជាតិ។





*ទិដ្ឋភាពក្នុងពិធីប្រកាសចូលកាន់តំណែងអគ្គលេខាធិការរងព្រឹទ្ធសភា*





*ទិដ្ឋភាពក្នុងពិធីប្រកាសចូលកាន់តំណែងអគ្គលេខាធិការរងព្រឹទ្ធសភា*

ក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានោះ **ឯកឧត្តមអនុប្រធានទី១** បានសម្តែងការកោតសរសើរចំពោះ **ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា** ថ្នាក់ដឹកនាំ និងសហការី នៃអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលបានខិតខំប្រឹងប្រែងបំពេញការងារអស់ពីកម្លាំងកាយ-ចិត្ត ប្រាជ្ញា និងស្មារតី ដោយសម្រេចបានសមិទ្ធផលការងារសំខាន់ៗជាច្រើន ក្នុងរយៈពេល១៩ខែកន្លងទៅ ជាពិសេសការងារអភិវឌ្ឍន៍ស្ថាប័ន ការងារកំណែទម្រង់ ក៏ដូចជាការយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព ឆ្លើយតបទៅនឹងតម្រូវការរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាក្នុងការបំពេញមុខងារ។

ជាចុងក្រោយ **ឯកឧត្តមអនុប្រធានទី១** បានផ្តាំផ្ញើដល់ថ្នាក់ដឹកនាំ និងមន្ត្រី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទាំងអស់សូមបន្តខិតខំបំពេញការងារ គោរពច្បាប់លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង វិន័យ និងក្រមសីលធម៌មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជំរុញសាមគ្គីភាព និងសហការល្អក្នុងការងារ សំដៅរួមចំណែកក្នុងការផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិកសមាជិកាព្រឹទ្ធសភាឱ្យបានគ្រប់ជ្រុងជ្រោយ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងគណនេយ្យភាព៕





*ឯកឧត្តម អ៊ុច បូរិទ្ធ ប្រគល់សេចក្តីសម្រេចតែងតាំង និងថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃសុក្រ ទី៣១ ខែតុលា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញដង្ហែសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីចម្រើនសេចក្តីសុខជូនព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង។



❈នាព្រឹកថ្ងៃអាទិត្យ ទី៩ ខែវិច្ឆិកា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា (៩ វិច្ឆិកា ១៩៥៣ - ៩ វិច្ឆិកា ២០២៥) និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ រាជធានីភ្នំពេញ។



❈នារសៀលថ្ងៃអង្គារ ទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញចូលរួមដង្ហែព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីពន្លត់ភ្លើងជ័យ នាឱកាសប្រារព្ធព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកានិងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥ នៅវិមានឯករាជ្យ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃចន្ទ ទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជានិងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី៣៣ ប្រចាំឆ្នាំ២០២៥ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃសៅរ៍ ទី៨ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញដាក់កម្រងផ្កានិងគោរពវិញ្ញាណក្ខន្ធបុព្វការីជន នៅវិមានឯករាជ្យ រាជធានីភ្នំពេញ ក្នុងឱកាសបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥។



❈នារសៀលថ្ងៃសៅរ៍ ទី៨ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភា បានអញ្ជើញថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ «ព្រះបរមរតនកោដ្ឋ» នៅមណ្ឌបតម្កល់ព្រះបរមរូប សួនច្បារខាងកើតវិមានឯករាជ្យ រាជធានីភ្នំពេញ ក្នុងឱកាសបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥។



❈នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យវឌ្ឍនភាពការងារនិងកំណត់ទិសដៅការងារបន្ត ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **នុត សារាន** ប្រធានគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម នៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខន្ធរ្យនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែតុលារបស់ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភានិងកំណត់ទិសដៅការងារសម្រាប់ខែបន្តបន្ទាប់ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខន្ធរ្យនា** អនុប្រធានទី២ព្រឹទ្ធសភានិងជាអនុប្រធានក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជាជាមួយសភាប្រឹក្សានយោបាយប្រជាជនចិន បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធនាវាពេទ្យសម្រាប់ «ជំនួយផ្នែកវេជ្ជសាស្ត្រ និងដឹកជញ្ជូនក្នុងគ្រោះមហន្តរាយ» នៅក្រុងថាយចូវ ខេត្តជឺជាំង នៃសាធារណរដ្ឋប្រជាមានិតចិន។




❈ចាប់ពីថ្ងៃសុក្រ ទី៣១ ខែតុលា រហូតដល់ថ្ងៃអាទិត្យ ទី២ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខន្ធរ្យនា** អនុប្រធានទី២ព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូចូលរួមវេទិកាវប្បធម៌សុខដុមនីយកម្មពិភពលោកឆ្នាំ២០២៥ (2025 Hehe Culture Global Forum) នៅខេត្តជឺជាំង នៃសាធារណរដ្ឋប្រជាមានិតចិន។




❈នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខន្ធរ្យនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាអនុប្រធានក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជា ជាមួយសភាប្រឹក្សានយោបាយប្រជាជនចិន អញ្ជើញជួបសំណេះសំណាលជាមួយលោក Zhao Cheng ជាប្រធានគណៈកម្មការឃោសនាបក្សកុម្មុយ-នីស្តចិនប្រចាំខេត្តជឺជាំង និងជួបពិភាក្សាជាមួយ លោក Chang Bo ប្រធានរដ្ឋបាលទំនាក់ទំនងប្រទេសចិន នៅក្រុងថាយចូវ ខេត្តជឺជាំង នៃសាធារណរដ្ឋប្រជាមានិតចិន។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែជាមួយប្រធានគណៈកម្មការទាំង ១០ព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា និងគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានគណៈកម្មការពិសេស បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការពិសេស ដើម្បីពិនិត្យនិងកែសម្រួលសេចក្តីស្នើច្បាប់វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឱ្យស្របតាមស្មារតីអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា មុនបញ្ជូនទៅរដ្ឋសភាតាមនីតិវិធីបន្ទាន់។



❈នាព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលដាច់ដោយឡែកពីគ្នាជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស នៃសាលាបឋមសិក្សាកោះដាច់ និងក្រុមប្រឹក្សាសង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភានិងទិសដៅការងារឆ្នាំ ២០២៦ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា៕



# ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី អញ្ជើញជាអធិបតីក្នុងពិធីបើកបវេសនកាល ឆ្នាំសិក្សា២០២៥-២០២៦ នៅវិទ្យាល័យ២៤កញ្ញា

ដើម្បីចូលរួមអបអរសាទរថ្ងៃបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០២៥-២០២៦ នៅព្រឹកថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ និងលោកជំទាវ **ម៉ែន ស៊ីន ម៉ុងឫទ្ធី** បានអញ្ជើញជាអធិបតីក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សា ២០២៥-២០២៦ នៅវិទ្យាល័យ ២៤កញ្ញា ស្ថិតក្នុងភូមិត្រពាំងកក់ ឃុំពោអង្គ្រង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ដោយមានការអញ្ជើញចូលរួមពីក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ថ្នាក់ដឹកនាំ អាជ្ញាធរស្រុកបរសេដ្ឋ ប្រធានមន្ទីរការិយាល័យអប់រំស្រុក ក្រុមប្រឹក្សាឃុំពោអង្គ្រង លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស សរុបជាង១.៥០០នាក់។




*ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី អញ្ជើញជាអធិបតីក្នុងពិធីបើកបវេសនកាល នៅវិទ្យាល័យ២៤កញ្ញា*

មានប្រសាសន៍សំណេះសំណាលក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត** បានលើកឡើងថា នេះជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់ សម្គាល់ពីការចាប់ផ្តើមនៃបរិបទសិក្សាថ្មី ដែលពោរពេញដោយក្តីសង្ឃឹម និងសេចក្តីរំភើបរីករាយសម្រាប់សិស្សានុសិស្ស ជាពិសេសសិស្សានុសិស្សថ្មីទាំងអស់។ **ឯកឧត្តមបណ្ឌិត** បានគូសបញ្ជាក់ថា បច្ចុប្បន្នក្រោមការដឹកនាំរបស់សម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងខិតខំឥតឈប់ឈរក្នុងការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ ជាពិសេសវិស័យអប់រំ។ **សម្តេច**បានផ្តោតលើការលើកកម្ពស់គុណភាពបង្រៀន និងរៀន ការអភិវឌ្ឍជំនាញគ្រូបង្រៀន ការបង្កើនឧបករណ៍បច្ចេកវិទ្យា និងបរិក្ខារសិក្សា ដើម្បីឆ្លើយតបទៅនឹងសម័យឌីជីថល និងការប្រកួតប្រជែងអន្តរជាតិ។ ការអប់រំល្អ គឺជាអាវុធដ៏ខ្លាំងបំផុត ដែលអាចផ្លាស់ប្តូរពិភពលោកបាន។ ដូចនេះ ប្អូនៗសិស្សានុសិស្សគួរតែយកការសិក្សាជាភារកិច្ចសំខាន់បំផុតក្នុងជីវិត និងប្រើប្រាស់ពេលវេលាទាំងអស់សម្រាប់រៀនសូត្រ ព្យាយាម និងបង្កើតសមត្ថភាពរបស់ខ្លួនឱ្យមានអនាគតភ្លឺស្វាងសម្រាប់ប្រទេសជាតិ និងសូមអនុវត្តតាមអនុសាសន៍របស់សម្តេចធិបតី **ហ៊ុន ម៉ាណែត** ដើម្បីក្លាយជាយុវជនឆ្នើម មានចរិតល្អ និងស្រឡាញ់ប្រទេសជាតិ។

ក្នុងឱកាសនោះដែរ **ឯកឧត្តមបណ្ឌិត** បានអញ្ជើញដាំកូនដើមឈើធ្នង់ និងព្រីង នៅក្នុងបរិវេណសាលាវិទ្យាល័យ ២៤កញ្ញា ព្រមទាំងបានឧបត្ថម្ភថវិកាដល់គណៈគ្រប់គ្រងវិទ្យាល័យ, ផ្លែឈើគ្រប់មុខជូនដល់អ្នកចូលរួមសរុបចំនួន ២.០០០ថង់ (ក្នុងមួយថង់ចំនួន៣គីឡូក្រាម) និងសៀវភៅ ៣ពាន់ក្បាល ប៊ិក៣ពាន់ដើម សម្រាប់ចែកជូនដល់សិស្សានុសិស្ស៕



*ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី អញ្ជើញដាំកូនដើមឈើ នៅក្នុងបរិវេណសាលាវិទ្យាល័យ ២៤កញ្ញា*

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# គណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងនាំយកព្រះរាជអំណោយ ជូនវីរកងទ័ពជួរមុខ ប្រចាំទិសមុំបី




*គណៈប្រតិភូគណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខវីរកងទ័ពជួរមុខ ប្រចាំទិសមុំបី*

នាព្រឹកថ្ងៃអង្គារ ទី២៨ ខែតុលា ឆ្នាំ២០២៥ គណៈប្រតិភូគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃព្រឹទ្ធសភា (គណៈកម្មការទី៨) និងក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការនិងជាប្រធានក្រុមសមាជិកា ដោយមានការយាងចូលរួមពី សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកាព្រឹទ្ធសភា បានយាង-អញ្ជើញចុះសួរសុខទុក្ខ និងនាំយកព្រះរាជអំណោយ និងអំណោយជាថ្នាំពេទ្យ គ្រឿងឧបភោគ បរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់មួយចំនួន ជូនវីរកងទ័ពជួរមុខនៅទីបញ្ជាការកងពលតូចអន្តរាគមន៍លេខ៩ ប្រចាំទិសមុំបី ខេត្តព្រះវិហារ។

ក្នុងឱកាសនោះ **លោកជំទាវប្រធាន** បាននាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខរបស់**សម្តេចតេជោ** ប្រធានព្រឹទ្ធសភា **ឯកឧត្តមអនុប្រធានទី១** និង**ឯកឧត្តមបណ្ឌិតអនុប្រធានទី២ព្រឹទ្ធសភា** ដែលតែងតែយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់វីរយុទ្ធជន ដែលបាននិងកំពុងឈរជើងយ៉ាងរឹងមាំ តស៊ូក្រាញននៀល ការពារទឹកដីមាតុភូមិកម្ពុជា និងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ដោយសារអំពើឈ្លានពានរបស់កងទ័ពថៃ។

**លោកជំទាវប្រធាន** បានជម្រាបថា នេះគឺជាលើកទី២និងជាការឆ្លើយតបចំពោះសំណូមពររបស់វីរកងទ័ព ព្រមទាំងចូលរួម ដើម្បីអបអរសាទរខួបលើកទី២១ នៃព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជានិងអបអរសាទរនៃការចុះសេចក្តីថ្លែងការណ៍រួមសន្តិភាពរវាងកម្ពុជា-ថៃ ក្រោមសក្ខីភាព ឯកឧត្តម **ដូណាល់ ត្រាំ** ប្រធានាធិបតីសហរដ្ឋអាម៉េរិក និងឯកឧត្តម **អាន់វ៉ា អ៊ីប្រាហ៊ីម** នាយករដ្ឋមន្ត្រីម៉ាឡេស៊ី ដែលជាកិច្ចព្រមព្រៀងសន្តិភាពលើកដំបូងជាប្រវត្តិសាស្ត្រសម្រាប់ជម្លោះព្រំដែនកម្ពុជា-ថៃ ដូចនេះ គណៈប្រតិភូបានអញ្ជើញចុះសួរសុខទុក្ខនាពេលនេះ ឆ្លុះបង្ហាញអំពីសាមគ្គីជាធ្លុងមួយ ខ្មែរស្រឡាញ់ខ្មែរ និងក្នុងស្មារតី ខ្មែរជួយខ្មែរ។




*លោកជំទាវ មាន សំអាន និងសម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី សំណេះសំណាលជាមួយវីរកងទ័ពជួរមុខ ប្រចាំទិសមុំបី*




*គណៈប្រតិភូគណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា នាំយកព្រះរាជអំណោយជូនវីរកងទ័ពជួរមុខ ប្រចាំទិសមុំបី*

**លោកជំទាវប្រធាន** បានបញ្ជាក់ថា ក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងជួបទុក្ខលំបាក គឺជាទុក្ខលំបាករបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា **សម្តេចព្រះមហាក្សត្រី** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា និង**សម្តេចធិបតី** នាយករដ្ឋមន្ត្រី ក្នុងការចាត់វិធានការនានា ដើម្បីការពារបូរណភាពដែនដីនិងដោះស្រាយវិវាទព្រំប្រទល់ជាមួយប្រទេសថៃដោយសន្តិវិធី ដោយផ្អែកលើច្បាប់អន្តរជាតិ លើធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន និងធ្វើឱ្យអន្តរជាតិទទួលស្គាល់ប្រទេសកម្ពុជា សំដៅជានាបាននូវសន្តិភាពប្រកបដោយចីរភាពជូនប្រជាជនទាំងពីរ គឺកម្ពុជានិងថៃ។

**លោកជំទាវប្រធាន** បានវាយតម្លៃខ្ពស់ និងសម្តែងនូវគោរវកិច្ចចំពោះវីរភាពអង់អាចក្លាហាន មោះមុតរបស់វីរយុទ្ធជនដែលបាននិងកំពុងលះបង់កម្លាំងកាយ-ចិត្ត បូជាសាច់ស្រស់ ឈាមស្រស់ ដើម្បីបុព្វហេតុការពារជាតិមាតុភូមិ។ ដោយឡែក **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា និង**សម្តេចធិបតី** នាយករដ្ឋមន្ត្រី ថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋនៅសមរភូមិក្រោយនៅតែបន្តគាំទ្រ និងផ្សារភ្ជាប់ជាមួយនឹងវីរយុទ្ធជននៅតាមសមរភូមិមុខ ក៏ដូចជាប្រជាជននៅទូទាំងប្រទេស និងប្តេជ្ញាដាច់ខាតការពារបូរណភាពដែនដី និងអធិបតេយ្យភាពនៃកម្ពុជា។

ព្រះរាជអំណោយ និងអំណោយជាថ្នាំពេទ្យ គ្រឿងឧបភោគ បរិភោគ និងសម្ភារៈប្រើប្រាស់ ជូនវីរកងទ័ពជួរមុខនៅទីបញ្ជាការកងពលតូចអន្តរាគមន៍លេខ៩ គឺជាព្រះរាជទានដ៏ថ្លៃថ្លាបំផុតរបស់ សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** គណៈកម្មការទី៨ព្រឹទ្ធសភា ក្រុមសមាជិកាព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ម៉ុខ ឫទ្ធី** និងលោកជំទាវ ព្រមទាំងសមាជិក សមាជិកាព្រឹទ្ធសភា។ គណៈប្រតិភូក៏បានឧបត្ថម្ភថវិកាមួយចំនួនដល់វរសេនាតូចអន្តរាគមន៍លេខ៣៩១, ៣៩២, ៣៩៣, ៣៩៤ និងវរសេនាតូចអន្តរាគមន៍លេខ៣៩៥ ចំណុះកងពលតូចអន្តរាគមន៍លេខ៩ ផងដែរ។

ក្រៅពីនេះ គណៈប្រតិភូបានអញ្ជើញចុះជួបសួរសុខទុក្ខ និងនាំយកព្រះរាជអំណោយ អំណោយ និងថវិកាមួយចំនួន ឧបត្ថម្ភជូនប្រជាពលរដ្ឋរងគ្រោះដោយគ្រាប់បែកចង្កោមនៅស្រុកជាំក្សាន្ត និងប្រជាពលរដ្ឋដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យបង្អែកខេត្ត ១៦មករា ខេត្តព្រះវិហារ។



*គណៈប្រតិភូគណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយវីរកងទ័ពជួរមុខ ប្រចាំទិសមុំបី*

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខនិងនាំយកចង្ក្រានសន្សំសំចៃថាមពលចែកជូនប្រជាពលរដ្ឋក្នុងស្រុកប្រាសាទសំបូរ និងនាំយកព្រះរាជអំណោយ គ្រឿងឧបភោគបរិភោគ ជូនកងពលតូចអន្តរាគមន៍លេខ៩ និងគ្រួសារកងទ័ពជួរមុខប្រចាំទិសមុំបី

គណៈប្រតិភូគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃព្រឹទ្ធសភា (គណៈកម្មការទី៨) ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈកម្មាធិការសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ បានអញ្ជើញចុះសួរសុខទុក្ខ និងនាំយកចង្ក្រានសន្សំសំចៃថាមពល សារុង និងក្រមា ចែកជូនប្រជាពលរដ្ឋចំនួន៣៤០គ្រួសារ នៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ និងនាំយកព្រះរាជអំណោយ គ្រឿងឧបភោគបរិភោគ ផ្លែឈើស្រស់ សម្ភារៈប្រើប្រាស់ និងថវិកាមួយចំនួន ជូនកងពលតូចអន្តរាគមន៍លេខ៩ និងគ្រួសាររវីរកងទ័ពជួរមុខចំនួន៥៥៥គ្រួសារ ប្រចាំទិសមុំបី ខេត្តព្រះវិហារ នៅទីបញ្ជាការកងពលតូចអន្តរាគមន៍លេខ៩ ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៥។



*លោកជំទាវ មាន សំអាន ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា (ពីឆ្វេងទី៣)*

ក្នុងពិធីទាំងនោះ **លោកជំទាវប្រធានគណៈប្រតិភូ** បាននាំយកប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខប្រកបដោយក្តីនឹករលឹកពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** និងសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ជូនគ្រួសារកងទ័ពនិងវីរយុទ្ធជនកំពុងឈរជើងយ៉ាងរឹងមាំ តស៊ូក្រាញននៀលការពារទឹកដីមាតុភូមិកម្ពុជា។ **លោកជំទាវប្រធាន** បានបន្តថា ទោះបីមានសភាពការណ៍ព្រំដែនកម្ពុជា-ថៃ កំពុងជួបបញ្ហាប្រឈមមុខដាក់គ្នាក៏ដោយ ក៏ប្រទេសជាតិយើងនៅតែបន្តបានសុខសន្តិភាព ស្ថិរភាពនយោបាយ និងជីវភាពរស់នៅល្អប្រសើរ។ ទន្ទឹមនោះ សូមឱ្យប្រជាពលរដ្ឋទាំងអស់ជឿជាក់ទៅលើរាជរដ្ឋាភិបាលដែលមាន សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការដឹកនាំចាត់ចែងការងារគ្រប់យ៉ាង ដើម្បីថែរក្សាសុខសន្តិភាព ការពារបូរណភាពទឹកដីឱ្យបានគង់វង្ស ដោយសន្តិវិធី នៅក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ និងស្មារតីពហុភាគី





*លោកជំទាវ មាន សំអាន សំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងស្រុកប្រាសាទសំបូរ*

និយម។ លោកជំទាវបានថ្លែងអំណរគុណ ចំពោះបងប្អូនជនរួមជាតិទាំងក្នុងនិងក្រៅប្រទេស រួមគ្នាជាធ្លុងមួយសម្តែងឆន្ទៈដើម្បីការពារអធិបតេយ្យជាតិ បូរណភាពទឹកដី និងការពារសេចក្តីថ្លៃថ្នូររបស់ខ្មែរ ដែលនេះគឺជាកម្លាំងចលករដ៏ខ្លាំងក្លាដែលគ្មានអ្នកណាមកបំបែក និងមកជាន់ពន្លិចបានឡើយ។



*គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា ចែកចង្រ្កានសន្សំសំចៃថាមពលជូនប្រជាពលរដ្ឋក្នុងស្រុកប្រាសាទសំបូរ*

**លោកជំទាវប្រធាន**បានលើកឡើងពីប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី**នាយករដ្ឋមន្ត្រី ចាត់ទុកយុទ្ធសាស្ត្រ «ស្ងាត់ តែមិនស្ងៀម» គឺជាយុទ្ធសាស្ត្រត្រឹមត្រូវក្នុងការដោះស្រាយបញ្ហាព្រំដែនកម្ពុជាជាមួយភាគីថៃ។ យុទ្ធសាស្ត្រនេះ បានបញ្ជាក់ពីសកម្មភាពសស់រវើករបស់រាជរដ្ឋាភិបាលដែលបានប្រឹងប្រែងដោះស្រាយបញ្ហាដោយភាពស្ងប់ស្ងាត់។ លោកជំទាវក៏បានជម្រាបដែរថា ការដោះស្រាយបញ្ហាព្រំដែនតាមយន្តការជាច្រើនដែលកំពុងតែដំណើរការក្នុងនោះប្រទេសកម្ពុជាបានអនុវត្តបទឈប់បាញ់ និងសេចក្តីថ្លែងការណ៍សន្តិភាពរវាងកម្ពុជានិងថៃ យ៉ាងម៉ឺងម៉ាត់ ហើយក្រុមការងារចម្រុះភាគីទាំងពីរបានចុះវាស់វែង និងបោះបង្គោលបណ្តោះអាសន្ននៅកំណាត់ខ្សែព្រំដែនចន្លោះបង្គោលព្រំដែនកម្ពុជា-ថៃ លេខ៤២ ដល់៤៧ ដែលស្ថិតនៅក្នុងភូមិសាស្ត្រឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

អំណោយជូនប្រជាពលរដ្ឋនៅស្រុកប្រាសាទសំបូរ ក្នុង១គ្រួសារទទួលបាន៖ អាហារ១កញ្ចប់ ចង្រ្កានសន្សំសំចៃថាមពលចំនួន១ និងសារុង១ ព្រមទាំងឧបត្ថម្ភដល់អនុសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ស្រុកប្រាសាទសំបូរនូវថវិកាមួយចំនួន។ ដោយឡែកនៅខេត្តព្រះវិហារ គណៈប្រតិភូបាននាំយកព្រះរាជអំណោយ និងអំណោយជូនកងពលតូចអន្តរាគមន៍លេខ៩ រួមមាន៖ Computer Laptop១គ្រឿង ឧបករណ៍ចាប់សញ្ញាGPS៥គ្រឿង គ្រឿងឧបភោគបរិភោគ ផ្លែឈើស្រស់ ភេសជ្ជៈ និងថវិកាចំនួន៥លានរៀល ព្រមទាំងគ្រួសាររើកងទ័ពចំនួន៥៥៥គ្រួសារ ដោយក្នុង១គ្រួសារទទួលបាន៖ អង្ករ១បាវ (ទម្ងន់២៥គីឡូក្រាម) ក្រមា១ សារុង១ ធុងចម្រោះទឹកស្អាត១ ភេសជ្ជៈ១កេស ទឹកបរិសុទ្ធ១កេស និងថវិកាចំនួន៣ម៉ឺនរៀល៕





*គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា នាំយកព្រះរាជអំណោយ គ្រឿងឧបភោគ បរិភោគ ជូនកងពលតូចអន្តរាគមន៍លេខ៩ និងគ្រួសារកងទ័ពជួរមុខប្រចាំទិសមុំបី*

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ប្រជាជនភៀសសឹកនៅភូមិព្រៃចាន់ និងភូមិជោគជ័យ ទទួលបានការពិនិត្យ និងព្យាបាលជំងឺដែលរៀបចំដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤



*ឯកឧត្តម ប៉ុល លឹម ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤*

ប្រជាជនភៀសសឹកនៅភូមិព្រៃចាន់និងភូមិជោគជ័យ ដែលទាហានថៃធ្វើការបាញ់ប្រហារយ៉ាងសាហាវព្រៃផ្សៃ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ កំពុងស្នាក់នៅទីកន្លែងសុវត្ថិភាព នៅវត្តចាន់ស៊ីសាមគ្គីរតនារាម ស្ថិតក្នុងឃុំអូរជ្រៅ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ត្រូវបានទទួលការយកចិត្តទុកដាក់ពិនិត្យនិងព្យាបាលជំងឺទូទៅដោយមិនយកកម្រៃពីក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជារបស់ប្រទេសបារាំង ក្រោមការដឹកនាំរបស់ឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **ធន់ ខឡុនា** អនុប្រធានទី២ព្រឹទ្ធសភា អមដំណើរដោយឯកឧត្តម **អ៊ុំ រាត្រី** អភិបាលខេត្តបន្ទាយមានជ័យ និងឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តបន្ទាយមានជ័យ និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។ ការពិនិត្យព្យាបាលជំងឺនេះ ប្រព្រឹត្តទៅរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី១៦ដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៥។

ក្នុងឱកាសនោះ **ឯកឧត្តមប្រធានក្រុមភូមិភាគទី៤** បានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខពី សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ និងឯកឧត្តមបណ្ឌិត **ធន់ ខឡុនា** អនុប្រធានទី២ព្រឹទ្ធសភា ប្រកបដោយក្តីនឹករលឹក និងតែងតែគិតគូរដល់សុខទុក្ខរបស់ប្រជាពលរដ្ឋគ្រប់ពេលវេលា។

ទន្ទឹមនឹងនេះ ឯកឧត្តមបានថ្លែងអំណរគុណចំពោះអាជ្ញាធរខេត្ត ស្រុក ដែលបានរៀបចំទីតាំង ការពារសន្តិសុខ សណ្តាប់ធ្នាប់ជូនប្រជាជនភៀសសឹកបានយ៉ាងល្អប្រសើរ ព្រមទាំងបានអរគុណដល់ក្រុមគ្រូពេទ្យប្រចាំការ និងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជារបស់ប្រទេសបារាំង ដែលបានយកចិត្តទុកដាក់ពិនិត្យសុខភាពជូនប្រជាពលរដ្ឋ។ ជាងនេះទៅទៀត **ឯកឧត្តមប្រធានក្រុមភូមិភាគទី៤** បានអំពាវនាវឱ្យប្រជាពលរដ្ឋកំពុងស្នាក់នៅក្នុងទីសុវត្ថិភាព មេត្តាអត់ធ្មត់ និងស្តាប់នូវការណែនាំរបស់អាជ្ញាធរនិងជឿជាក់ទៅលើការដឹកនាំប្រកបដោយពុទ្ធិបញ្ញាញាណឈ្លាសវៃ ប្រកាន់ខ្ជាប់នូវ



*ប្រជាជនភៀសសឹកនៅភូមិព្រៃចាន់ និងភូមិជោគជ័យ អញ្ជើញមកពិនិត្យ និងព្យាបាលជំងឺ*





*ទិដ្ឋភាពពិនិត្យ និងព្យាបាលជំងឺ ជូនប្រជាជនភៀសសឹកនៅភូមិព្រៃចាន់ និងភូមិជោគជ័យ*

សន្តិភាពនិងអហិង្សារបស់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ក្នុងការដោះស្រាយជម្លោះព្រំប្រទល់ជាមួយប្រទេសថៃ ដែលនឹងវិលត្រឡប់ទៅរកសភាពដើមវិញ។ ទន្ទឹមនឹងនេះ ក៏សូមប្រជាពលរដ្ឋខ្មែរទាំងអស់ មេត្តារួបរួមសាមគ្គីគ្នាជាធ្លុងមួយ ដើម្បីជាកម្លាំងចិត្តមួយដ៏កក់ក្តៅពោរពេញទៅដោយថាមពល ដល់រាជរដ្ឋាភិបាលនិងវីរយុទ្ធជនយើង ក្នុងការការពារបូរណភាពដែនដី និងជាតិមាតុភូមិនៃយើង។

ជាលទ្ធផល នៃការពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋក្នុងរយៈពេល២ថ្ងៃ មានប្រជាពលរដ្ឋសរុបចំនួន៤២២នាក់ ក្នុងនោះស្ត្រីចំនួន៣២០នាក់ បុរស៦៩នាក់ និងកុមារចំនួន៣៣នាក់។

ក្នុងឱកាសដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យនិងព្យាបាលជំងឺប្រជាពលរដ្ឋ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានអញ្ជើញនាំយកអំណោយជាសម្ភារៈមួយចំនួនរបស់ឯកឧត្តមបណ្ឌិត **ឆន់ ខឡុនា** អនុប្រធានទី២ ព្រឹទ្ធសភា ឯកឧត្តម **ម៉ម ប៊ុននាង** និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនរដ្ឋបាលខេត្តបន្ទាយមានជ័យ និងឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តបន្ទាយមានជ័យសម្រាប់ចែកជូនប្រជាពលរដ្ឋភៀសសឹក និងក្រុមគ្រួសារសពលោក **ឌី ណៃ** ដែលត្រូវទាហានថៃបាញ់សម្លាប់។





*ឯកឧត្តម ប៉ុល លឹម អញ្ជើញនាំយកអំណោយជាសម្ភារៈមួយចំនួន ជូនរដ្ឋបាលខេត្តបន្ទាយមានជ័យ*

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ប្រជាពលរដ្ឋស្រុកស្រីសន្ធរ ស្រុកស្ទឹងត្រង់ និងស្រុកពញាក្រែកទទួលបានការពិនិត្យនិងព្យាបាលជំងឺដែលរៀបចំដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២





*ឯកឧត្តម ឡាន់ ឆន សំណេះសំណាលជាមួយប្រជាពលរដ្ឋនៅស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ*

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ (ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ) រួមមាន ឯកឧត្តម **ឡាន់ ឆន** អនុប្រធាន និងឯកឧត្តម **ឌឹម លាច** សមាជិកក្រុម តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អមដំណើរដោយរដ្ឋបាលខេត្ត ស្រុក និងអាជ្ញាធរពាក់ព័ន្ធ បានដឹកនាំសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ក្រុមហ៊ុន Laboratoire Bioderma (ប្រទេសបារាំង) អញ្ជើញចុះពិនិត្យព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយមិនយកកម្រៃ នៅស្រុកស្រីសន្ធរ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម និងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាថ្ងៃទី២០ ថ្ងៃទី២១ និងថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៥។

មុននឹងក្រុមគ្រូពេទ្យពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋតាមស្រុកនីមួយៗ **ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២** បានសំណេះសំណាលជាមួយប្រជាពលរដ្ឋ ដោយបាននាំយកប្រសាសន៍ផ្ដាំផ្ញើសួរសុខទុក្ខនិងពរជ័យពីសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ និងឯកឧត្តមបណ្ឌិត **ឆន់ ខន្ធរ៉ា** អនុប្រធានទី២ព្រឹទ្ធសភា ជូនដល់បងប្អូនប្រជាពលរដ្ឋ និងបានអរគុណដល់អាជ្ញាធរពាក់ព័ន្ធ និងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ដែលបានរៀបចំទីកន្លែង និងពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ។

**ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២** បានក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋ សូមថែទាំសុខភាពឱ្យបានល្អគ្រប់ៗគ្នា តាមរយៈការហូបស្អាត រស់នៅស្អាត និងគោរពតាមការណែនាំរបស់គ្រូពេទ្យ ពីព្រោះថា ការថែទាំសុខភាព គឺជារឿងសំខាន់សម្រាប់ជីវិតយើងទាំងអស់គ្នា ដើម្បីឆ្ពោះទៅរកភាពជោគជ័យសុភមង្គលក្នុងក្រុមគ្រួសារនិងសង្គមជាតិ។





*ទិដ្ឋភាពពិនិត្យ និងព្យាបាលជំងឺ ជូនប្រជាពលរដ្ឋរស់នៅស្រុកពញាក្រែក*





*ឯកឧត្តម ជឹម លាវ សំណេះសំណាលជាមួយប្រជាពលរដ្ឋនៅស្រុកស្ទឹងត្រង់*

ក្នុងឱកាសនោះផងដែរ **ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២** បានជម្រាបជូនបងប្អូនប្រជាពលរដ្ឋ បានជ្រាបអំពីសភាពការណ៍វិវត្តថ្មីៗ នៃការរំលោភឈ្លានពានរបស់ថៃ មកលើបូរណភាពដែនដី និងអធិបតេយ្យភាពរបស់កម្ពុជា បើទោះបីជាមានសេចក្តីថ្លែងការណ៍រួមស្តីពី សន្តិភាព ដែលមានសហរដ្ឋអាម៉េរិក និងម៉ាឡេស៊ី ជាសាក្សីក៏ដោយ ក៏ថៃមិនឱ្យយើងមានសេចក្តីសុខ និងតែងតែចិញ្ចឹមចិត្តចង់បានទឹកដីយើងជានិច្ច។ ទន្ទឹមនឹងនេះ **ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២** បានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋមេត្តាអត់ធ្មត់និងជឿជាក់ទៅលើការដឹកនាំប្រកបដោយបញ្ញាញាណឈ្លាសវៃ ប្រកាន់ខ្ជាប់នូវសន្តិភាព និងអហិង្សា របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ក្នុងការដោះស្រាយជម្លោះព្រំប្រទល់ជាមួយប្រទេសថៃ ក្រោមយុទ្ធសាស្រ្ត «ស្ងាត់តែមិនស្ងៀម»។ ជាងនេះទៅទៀត **ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២** ក៏បានក្រើនរំលឹកផងដែរដល់ប្រជាពលរដ្ឋកុំឱ្យជឿលើការញុះញង់របស់ក្រុមជ្រុលនិយមមួយក្តាប់តូចនៅក្រៅប្រទេស ដែលតែងតែបំបែកបំបាក់សាមគ្គីជាតិ ដោយថារាជរដ្ឋាភិបាលកម្ពុជាកំពុងកាត់ទឹកដីឱ្យថៃ ក្នុងខណៈពេលដែលរាជរដ្ឋាភិបាលប្រទេសទាំងពីរ កំពុងតែចុះវាស់វែងបង្គោលខណ្ឌសីមាបណ្តោះអាសន្ននៅឡើយ។

តាមរយៈការពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋក្នុងរយៈពេល៣ថ្ងៃ មានប្រជាពលរដ្ឋសរុបចំនួន១.៩៧៥នាក់ ក្នុងនោះ នៅស្រុកស្រីសន្ធរ មានប្រជាពលរដ្ឋសរុបចំនួន៨៦០នាក់ (នារីចំនួន៣២៧នាក់ បុរសចំនួន២៦៣នាក់ កូនសិស្សចំនួន២៧០នាក់) អ្នកជំងឺកំពុងតាមដានចំនួន៣៤នាក់ (នារី១៨នាក់), នៅស្រុកស្ទឹងត្រង់ មានប្រជាពលរដ្ឋសរុបចំនួន៦៥៩នាក់ (នារីចំនួន១៩៩នាក់ បុរសចំនួន១៤៦នាក់ កូនសិស្សចំនួន៣០០នាក់) អ្នកជំងឺកំពុងតាមដានចំនួន១៤នាក់ (នារី៩នាក់) និងនៅស្រុកពញាក្រែក មានប្រជាពលរដ្ឋសរុបចំនួន៤៥៦នាក់ (នារីចំនួន២៨៨នាក់ បុរសចំនួន១៥០នាក់) អ្នកជំងឺកំពុងតាមដានចំនួន១៨នាក់ (នារី១៥នាក់)៕





*ទិដ្ឋភាពពិនិត្យ និងព្យាបាលជំងឺ ជូនប្រជាពលរដ្ឋរស់នៅស្រុកស្រីសន្ធរ*

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ សហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ប្រទេសបារាំង អញ្ជើញចុះពិនិត្យនិងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋនៅស្រុកស្អាង



ឯកឧត្តម ម៉ម ប៊ុននាង ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣

នាថ្ងៃចន្ទ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ (ខេត្តកណ្តាល) ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានក្រុម បានដឹកនាំសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ក្រុមហ៊ុន Laboratoire Bioderma (ប្រទេសបារាំង) អញ្ជើញចុះពិនិត្យនិងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយមិនយកកម្រៃ នៅឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល។

តាងនាមឱ្យក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានក្រុម បានមានប្រសាសន៍នាំនូវការផ្តាំផ្ញើការសួរសុខទុក្ខពីសំណាក់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា **ឯកឧត្តមអនុប្រធានទី១** និង **ឯកឧត្តមបណ្ឌិតអនុប្រធានទី២**ព្រឹទ្ធសភា ព្រមទាំងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ថ្នាក់ដឹកនាំស្រុក អាជ្ញាធរពាក់ព័ន្ធ និងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ដែលបានជួយសម្របសម្រួល និងសហការយ៉ាងរលូនឱ្យមានពិធីពិនិត្យនិងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយមិនយកកម្រៃ។

**ឯកឧត្តមប្រធានក្រុម** បានបញ្ជាក់ថា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឱ្យប្រទេសជាតិយើងសម្រេចបានជោគជ័យយ៉ាងធំធេងបង្កើតបាននូវសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រជាច្រើនលើគ្រប់វិស័យ។ **សម្តេចទាំងពីរ** តែងតែយកចិត្តទុកដាក់ចំពោះសុខុមាលភាពរបស់បងប្អូនប្រជាពលរដ្ឋគ្រប់មូលដ្ឋាន ដែលក្នុងនោះ វិស័យសុខាភិបាលគឺជាវិស័យអាទិភាពមួយ ដែលរាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ បង្វិតសេវាសុខភាពឱ្យកាន់តែកៀកជិតនឹងមូលដ្ឋាន ដើម្បីលើកកម្ពស់សុខុមាលភាព ដែលជាកត្តាចម្បងសម្រាប់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសុខភាពល្អសំដៅរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋយើង។

**ឯកឧត្តមប្រធានក្រុម** បានបញ្ជាក់បន្ថែមថា ក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃក្រុមហ៊ុន Laboratoire Bioderma របស់ប្រទេសបារាំង ចុះមកពិនិត្យនិងព្យាបាលជំងឺទូទៅជូនបងប្អូនប្រជាពលរដ្ឋដោយមិនយកកម្រៃ ព្រមទាំងផ្តល់ថ្នាំជូនទៅតាមប្រភេទជំងឺក្នុងស្មារតីមនុស្សធម៌ដែលស្តែងចេញពីទឹកចិត្តសប្បុរស សំដៅរួមចំណែកជាមួយរាជរដ្ឋាភិបាលជួយកាត់បន្ថយការលំបាករបស់ប្រជាពលរដ្ឋបានមួយចំណែក។ ជាមួយគ្នានេះ ឯកឧត្តមសង្ឃឹមថា ក្រុមគ្រូពេទ្យនឹងបន្តធ្វើការងារមនុស្សធម៌ជូនប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា ក៏ដូចជាចុះជួយនៅភូមិភាគទី៣និងភូមិភាគនានាជាបន្តបន្ទាប់ទៀត។

**ឯកឧត្តមប្រធានក្រុម** បានក្រើនរំលឹកដល់ប្រជាពលរដ្ឋនៅស្រុកស្អាងទាំងអស់ សូមថែទាំសុខភាពឱ្យបានល្អ ខិតខំថែរក្សាសុខភាពរបស់ខ្លួន ដោយត្រូវយល់ដឹងឱ្យបានច្រើនអំពីបញ្ហាអនាម័យតាមរយៈការហូបស្អាត រស់នៅស្អាត និងគោរពតាមការណែនាំរបស់គ្រូពេទ្យ និងការផ្សព្វផ្សាយរបស់ក្រសួងសុខាភិបាល និងភ្នាក់ងារសុខាភិបាល៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





ទិដ្ឋភាពពិនិត្យ និងព្យាបាលជំងឺ ជូនប្រជាពលរដ្ឋ

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមអភិវឌ្ឍន៍សុខុមាលភាពកម្ពុជា-បារាំង ចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋរស់នៅស្រុកគិរីវង់ ដោយឥតគិតថ្លៃ

នាថ្ងៃពុធ ទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ (ខេត្តកំពត ខេត្តតាកែវ និងខេត្តកែប) ដឹកនាំដោយឯកឧត្តម **ឈួន ឆាម** ប្រធានស្តីទីក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមអភិវឌ្ឍន៍សុខុមាលភាពកម្ពុជា-បារាំង បានអញ្ជើញចុះពិនិត្យព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋរស់នៅឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ ដោយឥតគិតថ្លៃ។



*ឯកឧត្តម ឈួន ឆាម ប្រធានស្តីទីក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥*

ក្នុងឱកាសនោះ ឯកឧត្តម **ឈួន ឆាម** ប្រធានស្តីទីក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥បានមានប្រសាសន៍នាំនូវការផ្តាំផ្ញើការសួរសុខទុក្ខពីសំណាក់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ ឯកឧត្តមបណ្ឌិត **ឆន់ ខឡុនា** អនុប្រធានទី២ព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែយកចិត្តទុកដាក់ និងគិតគូរអំពីសុខទុក្ខរបស់បងប្អូនប្រជាពលរដ្ឋទូទាំងប្រទេស ក៏ដូចជាប្រជាពលរដ្ឋរស់នៅក្នុងស្រុកគិរីវង់ ខេត្តតាកែវ។

**ឯកឧត្តមប្រធានស្តីទីក្រុម** បានបញ្ជាក់ថា បញ្ហាសុខភាព គឺជារឿងសំខាន់ណាស់ បើយើងមានសុខភាពល្អ គឺជាធនធាន ប៉ុន្តែបើយើងមានជំងឺ សុខភាពមិនល្អ គឺជាបន្ទុករបស់គ្រួសារ និងសង្គមជាតិ។ ក្នុងន័យនេះហើយទើបរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់សម្តេចតេជោ **ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនិងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា រហូតមកដល់ពេលនេះរាជរដ្ឋាភិបាលថ្មី ដែលដឹកនាំដោយសម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅតែបន្តចាត់ទុកការលើកកម្ពស់សេវាថែទាំសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ គឺជាអាទិភាពចម្បងបំផុត។ ជាមួយគ្នានេះ ឯកឧត្តមក៏បានអំពាវនាវឱ្យពុកម៉ែ បងប្អូន និងប្រជាពលរដ្ឋទាំងអស់ ត្រូវខិតខំថែរក្សាសុខភាពរបស់ខ្លួន ដោយត្រូវយល់ដឹងឱ្យបានច្រើនអំពីបញ្ហា





*ប្រជាពលរដ្ឋរស់នៅស្រុកគិរីវង់ អញ្ជើញមកពិនិត្យ និងព្យាបាលជំងឺ*





*ទិដ្ឋភាពពិនិត្យ និងព្យាបាលជំងឺ ជូនប្រជាពលរដ្ឋរស់នៅស្រុកគិរីវង់*

អនាម័យ និងសុខភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារ ស្តាប់តាមការណែនាំនិងការផ្សព្វផ្សាយរបស់ក្រសួងសុខាភិបាលនិងភ្នាក់ងារសុខាភិបាលគ្រប់ជាន់ថ្នាក់។

តាងនាមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ឯកឧត្តមបានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំស្រុកនិងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងស្រុកគិរីវង់និងសមាគមអភិវឌ្ឍន៍សុខុមាលភាពកម្ពុជា-បារាំង ដែលបានផ្តល់កិច្ចសហការយ៉ាងល្អ ធ្វើឱ្យកម្មវិធីរបស់យើងនៅថ្ងៃនេះប្រព្រឹត្តទៅដោយរលូនតាមកម្មវិធីគ្រោងទុក ដើម្បីជួយពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋរស់នៅឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ ដោយមិនយកកម្រៃ។ បន្ទាប់មកនៅព្រឹកថ្ងៃដដែល ស្ថិតនៅវត្តគិរីចុងកោះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន និងមេភូមិ នៅឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពនៃការអនុវត្តការងាររបស់ឃុំ ដែលបាននិងកំពុងមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ ជាពិសេសការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋបានយ៉ាងល្អប្រសើរ។

ដោយឡែកនៅរសៀលថ្ងៃដដែលនោះផងដែរ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានអញ្ជើញចុះពិនិត្យវឌ្ឍនភាព នៃការថែទាំនិងប្រើប្រាស់ស្រះទឹកវត្តទេព្យប្រណម្យ ដែលទំហំបណ្តោយ៤៨ម៉ែត្រ ទទឹង៣៨ម៉ែត្រ និងជម្រៅ៥,៥ម៉ែត្រ ស្ថិតនៅក្នុងឃុំអង្គប្រាសាទ ស្រុកគិរីវង់ និងស្រះទឹកភូមិថ្នល់បត់មានទំហំបណ្តោយ៥០ម៉ែត្រ ទទឹង៣២ម៉ែត្រ និងជម្រៅ៤,៧ម៉ែត្រ ស្ថិតនៅក្នុងឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ៕





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានអញ្ជើញចុះពិនិត្យវឌ្ឍនភាព នៃការថែទាំនិងប្រើប្រាស់ស្រះទឹកវត្តទេព្យប្រណម្យ និងស្រះទឹកភូមិថ្នល់បត់*

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ក្រុមសមាជិកាព្រឹទ្ធសភាអញ្ជើញចែកធុងចម្រោះទឹកស្អាតជូនដល់ប្រជាពលរដ្ឋរស់នៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង



*លោកជំទាវ មាន សំអាន ប្រធានក្រុមសមាជិកាព្រឹទ្ធសភា*

នាព្រឹកថ្ងៃអាទិត្យ ទី២៦ ខែតុលា ឆ្នាំ២០២៥ ក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយ លោកជំទាវ **មាន សំអាន** ប្រធានក្រុម និងជាអនុប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ ព្រមទាំងមានវត្តមានអមដំណើរពីសម្តេចព្រះរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាព្រឹទ្ធសភា លោកជំទាវតំណាងរាស្ត្រ លោកជំទាវប្រធាន អនុប្រធានកិត្តិយស លោកជំទាវប្រធានប្រតិបត្តិគណៈសាខាសមាគមនារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្ត ឯកឧត្តមអភិបាលរងខេត្ត បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខនិងនាំយកធុងចម្រោះទឹកស្អាតជាអំណោយរបស់ក្រុមហ៊ុន SIPCO ដំណាក់កាលទី២ ចែកជូនប្រជាពលរដ្ឋរស់នៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ចំនួន១.០៦៥គ្រួសារ។

ក្នុងឱកាសនោះ លោកជំទាវ **មាន សំអាន** បាននាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ដែលមានសម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជូនចំពោះបងប្អូនប្រជាពលរដ្ឋរស់នៅស្រុកទឹកផុស។ លោកជំទាវបានជម្រាបអំពីតួនាទីរបស់ព្រឹទ្ធសភានិងការដាក់ចេញនូវកិច្ចការជាអាទិភាពចម្បងចំនួនពីរគឺ៖១-ការអភិវឌ្ឍទំនាក់ទំនងអន្តរជាតិ លើកកម្ពស់ការទូតសភា ២-លើកកម្ពស់ភាពជាតំណាងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋទូទាំងប្រទេស។

**លោកជំទាវប្រធានក្រុម** បានថ្លែងអំណរគុណចំពោះប្រជាពលរដ្ឋរស់នៅក្នុងស្រុកទឹកផុស ដែលបានគាំទ្រ និងចូលរួមជាមួយរាជរដ្ឋាភិបាល អាណត្តិទី៧ ដឹកនាំដោយសម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើនូវកិច្ចការងារជាច្រើន និងធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យធ្វើឱ្យជីវភាពរបស់បងប្អូនប្រជាពលរដ្ឋកាន់តែល្អ។





*ប្រជាពលរដ្ឋរស់នៅស្រុកទឹកផុស អញ្ជើញចូលរួមក្នុងពិធីចែកធុងចម្រោះទឹកស្អាត*





*ក្រុមសមាជិកាព្រឹទ្ធសភាចែកធុងចម្រោះទឹកស្អាតជូនប្រជាពលរដ្ឋរស់នៅស្រុកទឹកផុស*

ក្នុងឱកាសនោះផងដែរ **លោកជំទាវប្រធានក្រុម** បានជម្រាបបងប្អូនប្រជាពលរដ្ឋឱ្យបានជ្រាបអំពីសភាពការណ៍ថ្មីៗរបស់ប្រទេសជាតិ ជាពិសេសជម្លោះព្រំដែនកម្ពុជា-ថៃ ដោយថ្មីៗនេះ គណៈប្រតិភូជាន់ខ្ពស់កម្ពុជាបានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការចម្រុះខ័ណ្ឌសីមាព្រំដែនគោកកម្ពុជា-ថៃ (JBC) នៅខេត្តចន្ទបុរី ប្រទេសថៃ ដែលភាគីថៃធ្វើជាម្ចាស់ផ្ទះ និងកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ (GBC) ព្រមទាំងចុះហត្ថលេខាលើឯកសារកិច្ចព្រមព្រៀងសន្តិភាពកម្ពុជា-ថៃ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ដោយទទួលបានលទ្ធផលជាវិជ្ជមានបន្ថែមទៀត ដើម្បីអនុញ្ញាតឱ្យភាគីទាំងពីរអាចបន្តជំរុញការអនុវត្តបទឈប់បាញ់ឱ្យមានប្រសិទ្ធភាពពេញលេញ សំដៅនាំមកនូវសន្តិភាព ស្ថិរភាព និងការវិលត្រឡប់ទៅរកប្រក្រតីភាពវិញបានឆាប់រហ័ស។ លទ្ធផលដ៏ត្រចះត្រចង់នេះ គឺជាអ្វីដែលពលរដ្ឋកម្ពុជាគ្រប់រូបទន្ទឹងរង់ចាំកន្លងមក  គឺការដោះស្រាយវិវាទព្រំដែនដោយសន្តិវិធី ដើម្បីចៀសវាងផលប៉ះពាល់នានា ទាំងការរស់នៅ និងការប្រកបរបរប្រចាំថ្ងៃឱ្យត្រឡប់មករកប្រក្រតីភាពឡើងវិញ។

ក្នុងនាមក្រុមសមាជិកាព្រឹទ្ធសភា លោកជំទាវបានគោរពដឹងគុណនិងថ្លែងអំណរគុណដល់ប្រមុខដឹកនាំកម្ពុជាដែលបានខិតខំយ៉ាងស្វិតស្វាញក្នុងការទប់ស្កាត់និងកុំឱ្យរីករាលដាលស្ថានភាពជម្លោះកម្ពុជា-ថៃឱ្យកាន់តែធំ ហើយអាចដោះស្រាយជម្លោះដោយយុទ្ធសាស្ត្រត្រជាក់ «ស្ងាត់តែមិនស្ងៀម» ដែលឈានទៅដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាព នៅប្រទេសម៉ាឡេស៊ី។



*ក្រុមសមាជិកាព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយប្រជាពលរដ្ឋរស់នៅស្រុកទឹកផុស*

**លោកជំទាវប្រធានក្រុម** បានគូសបញ្ជាក់ថា ការចែកធុងចម្រោះទឹកស្អាតជាអំណោយក្រុមហ៊ុន SIPCO ជូនបងប្អូនប្រជាពលរដ្ឋ គឺដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់គ្នាចូលរួមសន្សំសំចៃថាមពលនិងការពារបរិស្ថាន រួមចំណែកការពារសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន និងចូលរួមចំណែកក្នុងការកាត់បន្ថយនូវការចំណាយរបស់បងប្អូនប្រជាពលរដ្ឋ។ លោកជំទាវក៏បានចែកជូនធុងចម្រោះទឹកស្អាតដល់ប្រជាពលរដ្ឋចំនួន១.០៦៥គ្រួសារ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនដល់អាជ្ញាធរស្រុកផងដែរ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# សិក្ខាកាមកម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់នៃសាលាភូមិន្ទរដ្ឋបាល អញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា

សាស្ត្រាចារ្យ ព្រះសង្ឃ និងសិក្ខាកាមកម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ថ្នាក់វិន័យ ឆ្នាំ២០២៥ នៃសាលាភូមិន្ទរដ្ឋបាលចំនួន៦៨អង្គ/នាក់ បាននិមន្តនិងអញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅរសៀលថ្ងៃព្រហស្បតិ៍ ទី៣០ ខែតុលា ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា។



*ឯកឧត្តម ប៉ុល លឹម អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា*

ក្នុងឱកាសនោះ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន នៃព្រឹទ្ធសភា (គណៈកម្មការទី៤) និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានស្វាគមន៍ និងជម្រាបជូនសិក្ខាកាមកម្មសិក្សាការី អំពីប្រវត្តិរបស់ព្រឹទ្ធសភា តាមសម័យកាលនីមួយៗ ចាប់តាំងពីឆ្នាំ១៩០៤ រហូតដល់សម័យបច្ចុប្បន្ននេះ។

ឯកឧត្តមបានបញ្ជាក់ប្រាប់ថា ព្រឹទ្ធសភា នីតិកាលទី១ ចាប់បដិសន្ធិដោយការចាត់តាំង បានចាប់ដំណើរការនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩។ ចាប់ពីនីតិកាលទី២ ព្រឹទ្ធសភាកើតឡើងតាមរយៈការបោះឆ្នោតជ្រើសតាំងជាអសកល មិនចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ ព្រឹទ្ធសភាមានសមាជិកយ៉ាងច្រើន ស្មើនឹងពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល សមាជិកព្រឹទ្ធសភា២រូបចាត់តាំងដោយព្រះមហាក្សត្រ ២រូបជ្រើសតាំងដោយរដ្ឋសភា ក្រៅពីនេះសមាជិកចំនួន៥៨រូប ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកល។

អាណត្តិរបស់ព្រឹទ្ធសភាមានរយៈពេល៦ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។ ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនម្ដងមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ។ ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភាត្រូវសម្រេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិច នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។







*សាស្ត្រាចារ្យ ព្រះសង្ឃ និងសិក្ខាកាមកម្មសិក្សាការីស្ដាប់បទបង្ហាញអំពីព្រឹទ្ធសភា*

ឯកឧត្តមបានជម្រាបបន្ថែមថា ព្រឹទ្ធសភា នីតិកាលទី៥ មានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រធានព្រឹទ្ធសភា ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ និង ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី២។ ដោយមានភាពចាំបាច់ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា បានផ្ទេរទៅបំពេញភារកិច្ចថ្មី អង្គព្រឹទ្ធសភាបានបោះឆ្នោតជ្រើសរើស ឯកឧត្តម **អ៊ុច បូររិទ្ធ** ជាអនុប្រធានទី១ និង ឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** ជាអនុប្រធានទី២ព្រឹទ្ធសភា។



ព្រឹទ្ធសភាបានបង្កើតនូវក្រុមយន្តការនានារបស់ខ្លួន រួមមាន៖ គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា ក្រុមនានាផ្សេងទៀត ព្រមទាំងក្រុមមិត្តភាពទ្វេភាគី ពហុភាគីជាមួយបណ្តាសភាបរទេសនៅលើពិភពលោក។

ក្រៅពីមុខងារស្នូលទាំងបីរបស់ព្រឹទ្ធសភា (មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង) ឯកឧត្តម **ប៉ុល លឹម** បានគូសបញ្ជាក់អំពី ការងារអាទិភាពចម្បងចំនួន២ របស់ព្រឹទ្ធសភា នីតិកាលទី៥ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតខ្ពស់របស់**សម្តេចតេជោ** ប្រធានព្រឹទ្ធសភា គឺការអភិវឌ្ឍទំនាក់ទំនងអន្តរជាតិ តាមរយៈការលើកកម្ពស់ការទូតសភានិងបង្កើនភាពជិតស្និទ្ធជាមួយអង្គបោះឆ្នោត នៃក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋនៅមូលដ្ឋាន។ ទន្ទឹមនឹងនេះ ព្រឹទ្ធសភាក៏មានមុខងារគាំទ្រចំនួនពីរទៀត គឺមុខងារសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍន៍ស្ថាប័ន។ ឯកឧត្តមក៏បានលើកឡើងផងដែរអំពី ការបង្កើតអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលជាសេនាធិការឱ្យព្រឹទ្ធសភាទទួលបន្ទុករ៉ាប់រងរាល់កិច្ចការរដ្ឋបាល សន្តិសុខ និងសេវាទាំងឡាយរបស់ព្រឹទ្ធសភា ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅព្រឹទ្ធសភា ក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់ប្រធានព្រឹទ្ធសភា។



បន្ទាប់ពីបានស្តាប់បទបង្ហាញរួចមក សិក្ខាកាមកម្មសិក្សាការី បាននិមន្តនិងអញ្ជើញទស្សនាសាលប្រជុំព្រឹទ្ធសភា និងអគារប្រវត្តិសាស្ត្រនានា នៅក្នុងបរិវេណព្រឹទ្ធសភា៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*សាស្ត្រាចារ្យ ព្រះសង្ឃ និងសិក្ខាកាមកម្មសិក្សាការី អញ្ជើញទស្សនាអគារនានាព្រឹទ្ធសភា*

# កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមតួមិត្តភាគ និងក្រុមនានានៃព្រឹទ្ធសភា

## ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១ព្រឹទ្ធសភា ចំនួន១លើក



នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឱ ច័ន្ទផល** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-របាយការណ៍សកម្មភាពនិងលទ្ធផលការងាររបស់គណៈកម្មការប្រចាំខែវិច្ឆិកា និងទិសដៅការងារសម្រាប់ខែធ្នូ ឆ្នាំ២០២៥

២-អំពីផែនការប្រតិបត្តិរបស់គណៈកម្មការប្រចាំឆ្នាំ ២០២៦

៣-បញ្ហាផ្សេងៗ។

## ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី២ព្រឹទ្ធសភា ចំនួន២លើក៖

ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នាព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-របាយការណ៍ប្រចាំខែ

២-ស្តាប់បទបង្ហាញរបស់ក្រុមហ៊ុនធុរវន្តឡើន

៣-បញ្ហាផ្សេងៗ។

-កិច្ចប្រជុំការងារ ដើម្បីពិភាក្សារៀបចំត្រៀមប្រជុំតាមប្រព័ន្ធនិម្មិត នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ លើការងារប្រយុទ្ធប្រឆាំងជំងឺរាតត្បាតសកល នារសៀលថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥។

## ❈គណៈកម្មការទី២ព្រឹទ្ធសភា ជួបភ្ញៀវអន្តរជាតិ ចំនួន១លើក



នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការ បានទទួលបដិសណ្ឋារកិច្ចគណៈ-ប្រតិភូសភាប្រឹក្សានយោបាយប្រជាជនចិន ដឹកនាំដោយឯកឧត្តម **វ៉ាង គួរសឹង** (Wang Guosheng) សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច នៃសភាប្រឹក្សានយោបាយប្រជាជនចិន (CPPCC) នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

## ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៤ព្រឹទ្ធសភា ចំនួន១លើក



នាព្រឹកថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង

គណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើផែនការសកម្មភាពការងាររបស់គណៈកម្មការប្រចាំឆ្នាំ២០២៦។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ចំនួន១លើក



នាព្រឹកថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដើម្បីពិនិត្យផែនការប្រតិបត្តិឆ្នាំ២០២៦ របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា ចំនួន២លើក៖

ឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នាព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-ការបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំខែតុលា ឆ្នាំ២០២៥

២-សេចក្តីព្រាងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៦

៣-ការបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែតុលា ឆ្នាំ២០២៥

៤-បញ្ហាផ្សេងៗ។

-កិច្ចប្រជុំផ្ទៃក្នុងក្រុមជំនួយការគណៈកម្មការ នារសៀលថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងច្បាប់ ដែលរដ្ឋសភាបញ្ជូនមកព្រឹទ្ធសភានាពេលខាងមុខ និងបញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ចំនួន២លើក៖

-នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឈិត សុខុន**



ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-ស្តាប់របាយការណ៍ស្តីពី លទ្ធផលការងាររបស់គណៈ-កម្មការប្រចាំខែវិច្ឆិកានិងទិសដៅការងារខែធ្នូ ឆ្នាំ២០២៥

២-ពិនិត្យកែសម្រួលនិងសម្រេចផែនការប្រតិបត្តិឆ្នាំ២០២៦ របស់គណៈកម្មការ

៣-ផ្សេងៗ។

-នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ាន់ ឈឿន**



អនុប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំជាមួយមន្ត្រីការិយាល័យជំនួយការគណៈកម្មការទី៧ព្រឹទ្ធសភា ដើម្បីពិនិត្យការងារសំខាន់ៗមួយចំនួនត្រៀមសម្រាប់កិច្ចប្រជុំប្រចាំខែវិច្ឆិការបស់គណៈកម្មការ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៨ព្រឹទ្ធសភា ចំនួន២លើក៖

-នារសៀលថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-ការបូកសរុបលទ្ធផលការងាររបស់គណៈកម្មការប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០២៥



២-ផែនការសកម្មភាពការងាររបស់គណៈកម្មការទី៨ព្រឹទ្ធសភាសម្រាប់ឆ្នាំ២០២៦

៣-បញ្ហាផ្សេងៗ។



-នាព្រឹកថ្ងៃចន្ទ ទី៣ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការ និងឯកឧត្តម **អ៊ុន ចណ្ណា** សមាជិកគណៈកម្មការ បានដឹកនាំកិច្ចប្រជុំជាមួយមន្ត្រីការិយាល័យអមគណៈកម្មការទី៨ព្រឹទ្ធសភា ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងផែនការសកម្មភាពការងារ ឆ្នាំ២០២៦និងបញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ចំនួន១លើក**



នាថ្ងៃព្រហស្បតិ៍ ទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-របាយការណ៍សកម្មភាពការងារប្រចាំឆ្នាំ២០២៥

២-ពិនិត្យឆ្លងផែនការសកម្មភាពការងារប្រចាំឆ្នាំ២០២៦

៣-បញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកាព្រឹទ្ធសភាចំនួន២លើក៖**



-នាព្រឹកថ្ងៃសុក្រ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកាព្រឹទ្ធសភា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-ការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥

២-ពិនិត្យផែនការសកម្មភាពការងារក្រុមប្រចាំឆ្នាំ២០២៦

៣-បញ្ហាផ្សេងៗ។

-នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវ **ឃួន ឃុនឌី** លេខាធិការក្រុមសមាជិកាព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំជាមួយមន្ត្រីការិយាល័យអមក្រុមសមាជិកាព្រឹទ្ធសភា ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងផែនការសកម្មភាពរបស់ក្រុមសមាជិកាព្រឹទ្ធសភាឆ្នាំ២០២៦និងពិនិត្យលើបញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៩ព្រឹទ្ធសភាចំនួន១លើក**

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារិទ្ធ**



ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-សេចក្តីព្រាងច្បាប់ចំនួន៦ ដែលនឹងមកដល់ព្រឹទ្ធសភាក្នុងពេលខាងមុខ

២-របាយការណ៍បូកសរុបលទ្ធផលនៃសកម្មភាពការងាររបស់គណៈកម្មការប្រចាំឆ្នាំ២០២៥ និងកម្មវិធីប្រតិទិន

ការងាររបស់គណៈកម្មការសម្រាប់ឆ្នាំ២០២៦

៣-របាយការណ៍ទូទាត់ថវិការបស់គណៈកម្មការប្រចាំឆ្នាំ ២០២៥

៤-បញ្ហាផ្សេងៗ។

### ❋កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ចំនួន១លើក



នាថ្ងៃព្រហស្បតិ៍ ទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យសម្រេចលើសេចក្ដីព្រាងរបាយការណ៍ស្ដីពី សកម្មភាពលទ្ធផលការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ និងលើកទិសដៅការងារបន្ត។

### ❋កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ចំនួន២លើក៖

ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានក្រុម បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖

-កិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៥ ដើម្បីត្រៀមលក្ខណៈដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃប្រទេសបារាំងប្រចាំនៅកម្ពុជា (AMH) ទៅខេត្តបន្ទាយមានជ័យ។

-កិច្ចប្រជុំជាមួយមន្ត្រីការិយាល័យអមក្រុមភូមិភាគទី១ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ ដើម្បីពិភាក្សាការងារលើ៖

១-ការកំណត់កាលបរិច្ឆេទ ទីកន្លែងសម្រាប់ត្រៀមរៀបចំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតកម្រៃ

២-ពិនិត្យនិងពិភាក្សាលើផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២៦៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

❋ឯកឧត្តម **ឌី ច័ន្ទផល** ប្រធានគណៈកម្មការទី១ ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមក្នុងមហាសន្និបាត សហភាពអន្តរសភាលើកទី ១៥១និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៥។

-ចូលរួមក្នុងកិច្ចប្រជុំសភាស្របពេលកិច្ចប្រជុំលើកទី៣០ នៃសន្និសីទភាគីក្របខ័ណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពី ការប្រែប្រួលអាកាសធាតុ នៅទីក្រុង Belém ប្រទេសប្រេស៊ីល ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៥។



❋ឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញ៖



-បំពេញទស្សនកិច្ចការងារនៅអគ្គលេខាធិការដ្ឋានអាយ៉ា

នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូណេស៊ី នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត **កៅ គឹមហួន** ជាអគ្គលេខាធិការអាស៊ាន នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូណេស៊ី នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៥។



❉ចាប់ពីថ្ងៃទី២៧ ខែតុលា ដល់ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញអមដំណើរសម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមវេទិកាសន្តិភាព ទីក្រុងប៉ារីស ស្តីពី «សម្ពន្ធភាពថ្មី ដើម្បីសន្តិភាព ប្រជាជន និងភពផែនដី» នៅទីក្រុងប៉ារីស សាធារណរដ្ឋបារាំង។

❉ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្តាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការចូលរួមរបស់ប្រជាពលរដ្ឋ និងសភាបើកចំហសម្រាប់អភិបាលកិច្ចប្រកបដោយបរិយាបន្ន និងដែលឆ្លើយតប សម្រាប់ឆ្នាំ២០២៦ នៅទីក្រុងវៀងចន្ទន៍ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។





❉នាថ្ងៃសៅរ៍ ទី២៩ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ាន់ ចំរើន** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំបន់អាស៊ី (APA) ស្តីពី កិច្ចការសង្គម និងវប្បធម៌ ដែលប្រព្រឹត្តទៅពីថ្ងៃទី២៨ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ នៅទីក្រុងមូស្គូ សហព័ន្ធរុស្ស៊ី។

❉ចាប់ពីថ្ងៃទី២៩ ខែតុលា ដល់ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **សេខ ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមមហាសន្និបាតលើកទី១៥ និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិលើកទី៥១ នៃក្រុមប្រឹក្សាសេរីនិយម និងប្រជាធិបតេយ្យអាស៊ី (Council of Asian Liberals and Democrats) នៅទីក្រុងបាងកក ប្រទេសថៃ៕

## ការទទួលពាក្យបណ្តឹង

❉ក្នុងខែវិច្ឆិកា ឆ្នាំ២០២៥ គណៈកម្មការទី១ព្រឹទ្ធសភា បានទទួលពាក្យបណ្តឹងចំនួន៧បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធចំនួន៥បណ្តឹង កំពុងពិនិត្យសិក្សាចំនួន៨បណ្តឹង តម្កល់ទុកមិនចាត់ការចំនួន១បណ្តឹង ផ្ញើលិខិតរំលឹកជំរុញការដោះស្រាយចំនួន៥បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន៥បណ្តឹង ផ្ញើកំណត់បង្ហាញគោរពរាយការណ៍ជូន **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា អំពីការឆ្លើយតបលទ្ធផលដោះស្រាយបណ្តឹងរបស់ក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធចំនួន៥បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹងចំនួន១៦បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន៤បណ្តឹង៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារ នៅតាមបណ្តាភូមិភាគទាំង៨

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភា បានអញ្ជើញ៖



-ដឹកនាំគណៈប្រតិភូគណៈកម្មការទី៣ព្រឹទ្ធសភា ជួបសំណេះសំណាលប្រជាពលរដ្ឋនិងពិនិត្យសកម្មភាពក្រុមការងារបច្ចេកទេសគ្រឿងចក្រកំពុងជួសជុលផ្លូវមួយខ្សែ ប្រវែង៧.០០០ម៉ែត្រ តភ្ជាប់ពីភូមិវាលវង់ ភូមិស្រះស្រង់ ភូមិត្រពាំងកែស ភូមិត្រពាំងដំរី និងភូមិព្រៃស្បា ស្ថិតក្នុងឃុំសែនជ័ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខ ព្រមទាំងណែនាំកម្មករអំពីរបៀបបណ្តុះថ្នាលកូនឈើដាំដើមឆ្នាំ២០២៥ ដើម្បីបរិស្ថានស្អាត និងភាពបៃតងនៃភពផែនដី នៅឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារចុះពិនិត្យមើលហេដ្ឋារចនាសម្ព័ន្ធនានា ទំនប់ទឹក និងប្រព័ន្ធធារាសាស្ត្រផ្សេងៗ នៅភូមិដូនអាត់ ឃុំសែនជ័ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នៅថ្ងៃទី២៦ ខែតុលា និងថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខកម្មករ ព្រមទាំងពិនិត្យការងារដាំដុះដំណាំកសិផលនិងការងារអភិវឌ្ឍសហគមន៍ដំណាំជូនប្រជាពលរដ្ឋ នៅភូមិមហាលំពាំងទី១ ឃុំសែនជ័ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋប្រកបរបរប្រចូតស្មៅលក់ នៅភ្នំម្រះព្រៅ ឃុំសែនជ័ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋដែលបានអញ្ជើញមកសម្រាកនិងជិះឡូរីកំសាន្ត នៅតំបន់កសិ-ទេសចរណ៍ ម៉ុងឫទ្ធី សែនជ័យ នៅភូមិមហាលំពាំងទី២ ឃុំសែនជ័ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ជួបសំណេះសំណាលនិងសួរសុខទុក្ខកម្មករ ព្រមទាំងពិនិត្យសកម្មភាពក្រុមការងារគ្រឿងចក្រ ដែលកំពុងសាងសង់គ្រឹះផ្លូវ ដើម្បីចាក់ក្រាលកៅស៊ូ DBST ចំនួនពីរស្រទាប់ឱ្យរួចរាល់មុនរដូវភ្លៀងមកដល់ងាយស្រួលដល់ប្រជាពលរដ្ឋ និងកម្មករក្នុងការធ្វើដំណើរ នៅឃុំសែនជ័ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ដឹកនាំក្រុមការងារកសិកម្ម កសិ-ឧស្សាហកម្ម ចុះពិនិត្យដំណើរការនៃសកម្មភាពរោងចក្រកៀបយកប្រេងគ្រាប់ក្នុងផ្លែដូងប្រេង ដែលមានកម្លាំងផលិត៦០តោនក្នុងមួយថ្ងៃ និងរោងចក្រចម្រាញ់កៀបយកសាច់ក្រៅផ្លែដូងប្រេង ដែលមានកម្លាំងផលិត៦០តោនក្នុងមួយថ្ងៃ ព្រមទាំងចុះពិនិត្យថ្នាលបណ្តុះកូនដូងប្រេងចំនួន១០០.០០០ដើម ដែលគ្រោងនឹងយកទៅដាំជំនួសដើមដូងប្រេងចាស់ហួសអាយុ នាដើម

រដូវវស្សា ខែឧសភា ឆ្នាំ២០២៦ ខាងមុខនេះ នៅក្នុងតំបន់អន្លង់ក្រពើ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ដឹកនាំក្រុមការងារកសិកម្ម កសិ-ឧស្សាហកម្ម អញ្ជើញពិនិត្យដំណើរការរោងចក្រផលិតកែច្នៃចំណីសត្វ ដែលអាចផលិតចំណីសត្វបានជាមធ្យម៧០០តោនក្នុងមួយថ្ងៃ ដោយរោងចក្រនេះអាចជួយប្រមូលទិញកសិផលពីកសិករ ដូចជាកន្ទក់ ចុងអង្ករ ដំឡូងមីហាលស្ងួត និងពោតក្រហម។ល។ បើគិតជាទឹកប្រាក់ប្រមាណជាង៤០ម៉ឺនដុល្លារសហរដ្ឋ-អាម៉េរិក នឹងអាចជួយផ្តល់ការងារជាងមួយម៉ឺនកន្លែង ដល់ប្រជាជនកម្ពុជាដោយផ្ទាល់និងដោយប្រយោល ព្រមទាំងជួយកាត់បន្ថយការនាំចូលចំណីសត្វ សាច់សត្វជាច្រើនប្រភេទមកពីបរទេស នៅភូមិមនោរម្យ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នារសៀលថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ដឹកនាំក្រុមការងារបច្ចេកទេសកសិកម្មចុះពិនិត្យកសិដ្ឋានចិញ្ចឹមត្រីនិងបានបង្ហាត់បង្រៀនដល់បុគ្គលិក កម្មករ សិស្សនិស្សិត ឱ្យមានចំណេះដឹងផ្នែកចិញ្ចឹមត្រី នៅភូមិឫទ្ធី១ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ចុះសួរសុខទុក្ខកម្មករនិងដឹកនាំក្រុមការងារផ្នែកបច្ចេក-ទេសគ្រឿងចក្រមកពិនិត្យមើលសកម្មភាពចាប់ផ្តើមចាក់ក្រាលថ្មមិចM30 នៅលើផ្លូវប្រវែង១.០៤០ម៉ែត្រ ក្នុងភូមិ



ស្វាយជង្គុំ ឃុំស្ពុះ ដែលតភ្ជាប់ពីភូមិព្រៃខ្សាំ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានប្រវែង៣.៥០០ម៉ែត្រ នាព្រឹកថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៥។

❈នាព្រឹកថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **ឈួន ឆាម** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងលោកជំទាវ **គង់ សៅវ៉េឆន** សមាជិកាគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចុះពិនិត្យស្រះទឹកក្រាំងលាវ និងសាលាដំណាក់ដែលបានជួសជុលរួច មានទំហំ១១ម៉ែត្រx៨ម៉ែត្រ នៅបណ្តោយផ្លូវជាតិលេខ២ ចន្លោះបង្គោលគីឡូម៉ែត្រលេខ៤៩-៥០ ភ្នំពេញ-តាកែវ កសាងដោយឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** និងលោកជំទាវ **ម៉ែន ស៊ីន ម៉ុងឫទ្ធី** ក្នុងឆ្នាំ១៩៩៧ នៅឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ។

❈នារសៀលថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខជាមួយប្រជាពលរដ្ឋ រស់នៅ ឃុំបឹងជ័រ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។



❈នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបូជាសពឯកឧត្តម **ឆាយ សារ៉េត** ទីប្រឹក្សារាជរដ្ឋាភិបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡា-

ហោម **ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះ-រាជាណាចក្រកម្ពុជា នៅបរិវេណវត្តពោធិ៍វាល សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

❋ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមជាមួយក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ចុះពិនិត្យការដ្ឋានអ៊ុតកៅស៊ូAC ប្រវែង៤៩៦ម៉ែត្រ នៅផ្លូវលេខ១៥០ ភូមិ៩ និងផ្លូវលេខ១៥៦ ភូមិ១០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នៅថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ចូលរួមជាមួយកាកបាទក្រហម សមាគមនារីដើម្បីសន្តិភាពនិងការអភិវឌ្ឍនិងក្រុមការងារសមាគមសិស្ស-និស្សិត អ.ម.ត ខណ្ឌទួលគោក ជួបសំណេះសំណាលសួរ-សុខទុក្ខប្រជាពលរដ្ឋចាស់ជរា ជនពិការ សរុបចំនួន៥៣ គ្រួសារ ព្រមទាំងបានឧបត្ថម្ភអង្ករ កន្សែងពោះគោ និងថវិកាមួយចំនួន ក្នុងសង្កាត់ទាំង១០ ខណ្ឌទួលគោក រាជធានីភ្នំពេញ នៅថ្ងៃទី១២ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥។

❋នាព្រឹកថ្ងៃសៅរ៍ ទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តការងារក្នុងរយៈពេល៩ខែ និងទិសដៅការងារប្រចាំត្រីមាសទី៤ ឆ្នាំ២០២៥ របស់ស្រុកកំពង់រោទិ៍ នៅសាលប្រជុំធំស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។



❋នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចុះពិនិត្យស្ថានភាពទឹកភ្លៀង នៅឃុំឈើទាល និងឃុំស្វាយធំ ដែលមានផលប៉ះពាល់ដល់ស្រែវស្សារបស់ប្រជា-ពលរដ្ឋ ព្រមទាំងបានជួយជាថវិកាមួយចំនួន ដើម្បីដាក់លូបង្ហូរទឹកជូនប្រជាពលរដ្ឋ នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។

❋ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈ-កម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមជាមួយក្រុមប្រឹក្សាខេត្ត មន្ត្រីរាជការ យុវជន ស.ស.យ.ក កាកបាទក្រហម ក្រុមកាយឫទ្ធិនិងប្រជាពលរដ្ឋ ក្នុងព្រះរាជពិធីបុណ្យរុក្ខទិវា ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ រាត្រី** អភិបាល នៃគណៈអភិបាលខេត្ត នៅចន្លោះស្ពានទី២ និងទី៣ ផ្លូវជាតិលេខ៦ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយ-មានជ័យ ព្រមទាំងបានបន្តចូលរួមព្រះរាជពិធីបុណ្យខួបលើកទី២១ នៃការគ្រងព្រះបរមរាជសម្បត្តិរបស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះ-មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **ឡេង ទារី** ប្រធានក្រុមប្រឹក្សាខេត្ត នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០២៥។



-ចូលរួមគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **សុ សំអាន** ទីប្រឹក្សាអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រោម

អធិបតីភាពឯកឧត្តម **កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅគេហដ្ឋានសព ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥។



-ចូលរួមពិធីសំណេះសំណាលសិស្សានុសិស្សជ័យលាភីនិទ្ទេសA ចំនួន១២៦នាក់ ក្រោមអធិបតីភាពឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅសាលាខេត្តបន្ទាយមានជ័យ នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥។



-នាំយកបច្ច័យចូលរួមបុណ្យអង្គកឋិនទានសាមគ្គី ដើម្បីវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់កាលត្រីមាស នៅវត្តសុវណ្ណសិក្ខារាមព្រៃចាន់ ស្ថិតក្នុងភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ចូលរួមពិធីបើកបំភ្លឺភ្លើងប្រទីប ដើម្បីអបអរសាទរ



ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងអកអំបុក សំពះព្រះខែនាដងស្ទឹងសិរីសោភ័ណ នៅសង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នារសៀលថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ចូលរួមជាមួយក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត មន្ត្រីរាជការ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋក្នុងពិធីសំពះព្រះខែ អកអំបុក និងបណ្តែតប្រទីប នៅដងស្ទឹងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ចូលរួមមិទ្ទីញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧២



នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកានិងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ រាត្រី** អភិបាលខេត្ត នៅសាលាខេត្តបន្ទាយមានជ័យ នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ចូលរួមជាមួយក្រុមប្រឹក្សាចុះសួរសុខទុក្ខនិងនាំយកថវិកាមួយចំនួនជូនដល់ប្រជាពលរដ្ឋចំនួន៣នាក់ ដែលរងរបួស



ដោយការបាញ់ប្រហារពីទាហានថៃ នៅមន្ទីរពេទ្យមិត្តភាព ជប៉ុន-កម្ពុជា មង្គលបូរី ខេត្តបន្ទាយមានជ័យ ព្រមទាំងបាន បន្តចូលរួមបុណ្យសពប្រជាពលរដ្ឋចំនួន១នាក់ ស្លាប់ដោយ ការបាញ់ប្រហារពីទាហានថៃ នៅភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ចូលរួមជាមួយក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត ក្រុមប្រឹក្សា ស្រុកអភិបាលស្រុក ជួបសំណេះសំណាលនិងសួរសុខទុក្ខ ព្រមទាំងចែកអំណោយជូនប្រជាពលរដ្ឋភៀសសឹក មកពី ភូមិព្រៃចាន់ ភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ក្រោម អធិបតីភាពឯកឧត្តម **កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តចាន់ស៊ី-សាមគ្គីរតនារាម ភូមិកូបកើត ឃុំកូប ស្រុកអូរជ្រៅ ខេត្ត បន្ទាយមានជ័យ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥។

❈លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការ ទី៨ព្រឹទ្ធសភា បានអញ្ជើញ៖



-គោរពវិញ្ញាណក្ខន្ធសពលោកតា **ម៉ិន រេន** ឪពុកបង្កើត លោកជំទាវ **ម៉ិន សុនី** អភិបាលរង នៃគណៈអភិបាល ខេត្តកំពង់ឆ្នាំង នៅភូមិកោះកណ្តុរ ឃុំឆ្លូង ស្រុកឆ្លូង ខេត្ត ក្រចេះ នារសៀលថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥។

-ជាអធិបតីក្នុងពិធីប្រារព្ធខួបលើកទី២៧ ទិវាមនុស្សចាស់




កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី១ ខែតុលា ឆ្នាំ ២០២៥ នៅវត្តមហារ ភូមិមហារ ឃុំជ័យ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥។



-ចូលរួមពិធីដង្ហែ បណ្តែតប្រទីប និងបង្ហោះគោម ដើម្បី អបអរសាទរព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និង អកអំបុក សំពះព្រះខែ ជាមួយរដ្ឋបាលខេត្តកំពង់ធំ នៅដង-ស្ទឹងសែន ខេត្តកំពង់ធំ នាល្ងាចថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ចុះសួរសុខទុក្ខនិងនាំយកថវិកាមួយចំនួនជូនលោកស្រី **ខ្លូត វណ្ណារ៉ា** សមាជិកាក្រុមប្រឹក្សាក្រុងស្ទឹងសែន កំពុង សម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ក្នុងភូមិរោងចក្រ សង្កាត់ ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ នារសៀលថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៥។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមរំលែកមរណទុក្ខនិងគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិតាជឹប សង្កាត់អណ្ដូងខ្មែរ ក្រុងកំពត ខេត្តកំពត និងនៅក្នុងភូមិស្រែ សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត នារសៀលថ្ងៃទី២៧ និងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥។



-ចូលរួមរំលែកទុក្ខនិងគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិម៉ាក់ប្រាង្គ ឃុំកំពង់ក្រែង ភូមិត្រពាំងសង្កែ ភូមិកំពង់សំរោង ឃុំកំពង់សំរោង ស្រុកទឹកឈូ និងភូមិត្រើយកោះ សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត នារសៀលថ្ងៃទី៣ ទី៦ ទី៧ ទី៩ និងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋ នៅភូមិព្រៃថ្នង ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត នាល្ងាចថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ចូលរួមក្នុងវេទិកាសាធារណៈជាមួយក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យគាំទ្រនិងជំរុញ



ការអនុវត្តកម្មវិធីនយោបាយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលកម្ពុជា ស្ថិតក្នុងភូមិបឹងតារោង ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥។

❈ឯកឧត្តម **គង់ មុនីភា** សមាជិកគណៈកម្មការទី១ ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋដែលចង់ស្វែងយល់អំពីការអនុវត្តសិទ្ធិមនុស្ស នៅភូមិស្នោ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ នាព្រឹកថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋដែលចង់ស្វែងយល់អំពីសិទ្ធិមនុស្ស នៅឃុំជំពូវន្ត ស្រុកជុំគិរី ខេត្តកំពត នារសៀលថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋដែលចង់ស្វែងយល់អំពីសិទ្ធិមនុស្ស នៅសង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង នារសៀលថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋដែលចង់ស្វែងយល់អំពីសិទ្ធិមនុស្ស នៅឃុំឫស្សីស្រុក ស្រុកកៀនស្វាយ ខេត្តកណ្ដាល នារសៀលថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៥។

❈នារសៀលថ្ងៃទី១១ និងព្រឹកថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ញ៉ូវ សុខ** សមាជិកគណៈកម្មការទី២ ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យនិងគោរពវិញ្ញាណក្ខន្ធសព លោក **ខាំ ឌិន** អតីតប្រធានអគារពាណិជ្ជកម្មខេត្តពោធិ៍សាត់ នៅគេហដ្ឋាននៃសព ស្ថិតក្នុងក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

❈ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៥ ព្រឹទ្ធសភា ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា និងលោកជំទាវ **ថាក់ ឡានី** សមាជិកា

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ បានអញ្ជើញ៖

-ជួបសំណេះសំណាលនិងចុះសួរសុខទុក្ខជាមួយក្រុមប្រឹក្សាឃុំកំពង់ត្រឡាច ឃុំអំពិលទឹក ឃុំប្រេស នៃស្រុកកំពង់ត្រឡាច ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន នៅសាលាឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងចុះសួរសុខទុក្ខជាមួយក្រុមប្រឹក្សាឃុំតាជេស ឃុំសែប ឃុំឈូកស ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន នៅសាលាឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង នារសៀលថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៥។



❈នាព្រឹកថ្ងៃពុធ ទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ង៉ែត ចន្ថាទី** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចុះពិនិត្យការដ្ឋានដាក់លូមុខកាត់ទំហំ០.៦ម៉ែត្រ មានប្រវែង២៤៧ម៉ែត្រ នៅផ្លូវលេខ៥៩០ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។



❈នារសៀលថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវ **មុំ សណ្ណាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយចលនានារីមកពីភូមិ២ សរុបចំនួន១៣គ្រួសារ និងបានឧបត្ថម្ភថវិកាមួយចំនួនជូនដល់បងប្អូនប្រជាពលរដ្ឋចូលរួមក្នុងពិធីនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។



❈នាថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីដាក់កម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធក្នុងមិទ្ទីញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ នៅវិមានឯករាជ្យ ខេត្តកំពង់ឆ្នាំង។

❈ឯកឧត្តម **សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលនិងសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ព្រមទាំងប្រជាពលរដ្ឋនៅភូមិស្នោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ នាព្រឹកថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ព្រមទាំងប្រជាពលរដ្ឋនៅភូមិត្រពាំងព្រីង ឃុំជំពូវន្ត ស្រុកជុំគិរី ខេត្តកំពត នារសៀលថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ព្រមទាំងប្រជាពលរដ្ឋនៅភូមិវាលថ្នល់ ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ព្រមទាំងប្រជាពលរដ្ឋនៅភូមិស្វាយ សង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង នារសៀលថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៥៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ



❈នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៤៣រូប បានយាង/អញ្ជើញចូលរួមក្នុងសិក្ខាសាលា ដើម្បីស្វែងយល់អំពីការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្ដីព្រាងច្បាប់ស្ដីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ នៅវិមានរដ្ឋសភា។

❈នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួបលើកទី៧១ នៃការបង្កើតកងកម្លាំងស្វ័យការពាររបស់ជប៉ុន នៅស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។

❈ឯកឧត្តមបណ្ឌិត **ចែម វីឌ្យ៉ា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមកម្មវិធីពិសាអាហារការងារតាមសេចក្ដីអញ្ជើញរបស់**ឯកឧត្តមឯកអគ្គរដ្ឋទូតបារាំង**ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅ À Un Déjeuner À La Résidence De France-1 រាជធានីភ្នំពេញ នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥។

-ចូលរួមកម្មវិធីខួបលើកទី១០២ នៃសាធារណរដ្ឋតួកគីយេ នៅ Rosewood Hotel រាជធានីភ្នំពេញ នាយប់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥។

-ចូលរួមកម្មវិធីក្នុងឱកាសអបអរសាទរការចូលជាប្រវត្តិសាស្ត្ររបស់ទីម័រឡេស្តេជារដ្ឋសមាជិកទី១១ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) នៅសង្កាត់ជ័យជំនះ រាជធានីភ្នំពេញ នាល្ងាចថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥។

❈នៅថ្ងៃទី២៦ ខែតុលា និងថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញទទួលជំនួយមនុស្សធម៌លើកទី១៣របស់មូលនិធិសង្គ្រោះជីវិតសកល រួមមាន៖ ឧបករណ៍វេជ្ជសាស្ត្រ ឱសថ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃផ្សេងៗ នៅវិមានព្រឹទ្ធសភា។




❈ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖



-ទទួលបដិសណ្ឋារកិច្ចស្វាគមន៍និងជូនដំណើរនិវត្តន៍របស់គណៈប្រតិភូសភាប្រឹក្សានយោបាយប្រជាជនចិន ដឹកនាំដោយឯកឧត្តម **វ៉ាង គួរសឹង** (Wang Guosheng) សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច នៃសភាប្រឹក្សានយោបាយប្រជាជនចិន (CPPCC) ក្នុងឱកាសអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិតេជោ នាព្រឹកថ្ងៃទី៣ និងរសៀលថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវបេតុងចំនួន២ខ្សែ ខ្សែបង្គោលភ្លើងសូឡាតាមផ្លូវចំនួន២៨៨ដើម និងទីទួលចាក់សាប នៅឃុំពោធិ៍រៀង និងឃុំព្រែកអន្ទះ ស្រុកពោធិ៍រៀង ក្រោមអធិបតីភាពឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ នៅខេត្តព្រៃវែង នៅព្រឹកថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥។



❈នាព្រឹកថ្ងៃអង្គារ ទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និងឯកឧត្តម **ហេង ហាលីម** សមាជិកគណៈ-កម្មការទី៨ព្រឹទ្ធសភា តំណាងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ បានអញ្ជើញនាំយកបច្ច័យចូលបុណ្យគម្រប់ខួប៧ថ្ងៃ លោក **សំ នីតូ** ត្រូវជាកូនប្រសាររបស់ឯកឧត្តមបណ្ឌិត **គីម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា។

❈នាថ្ងៃពុធ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពី «សហគ្រិនភាពរបស់ស្ត្រីហ្វ្រង់-កូហ្វូន» នៃគណៈកម្មការកិច្ចការសេដ្ឋកិច្ច សង្គម និងបរិស្ថាន នៃសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធនិម្មិត នៅវិមានរដ្ឋសភា។



❈នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **គិន ណៃត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យបូជាសពលោកជំទាវ **កែវ គឹមសេង** ភរិយាសពឯកឧត្តមឧត្តមសេនីយ៍ឯក **ស្វាយ ញ៉ូន** អតីតរដ្ឋលេខា-ធិការក្រសួងការពារជាតិ នៅគេហដ្ឋាននៃសព នៅក្រុងដូនកែវ ខេត្តតាកែវ។

❈លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖

-ជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ចុះសួរសុខទុក្ខ និងប្រគេនបច្ច័យ ភេសជ្ជៈមួយចំនួនជូនព្រះអង្គគ្រូ **នី សុវណ្ណមុន្នីរ៉េត** ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរ-ពហុព្យាបាលអាស៊ី នាព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ចុះសួរសុខទុក្ខ និងនាំយកថវិកា សម្ភារៈមួយចំនួនជូនប្រជាពលរដ្ឋរងគ្រោះដោយព្រឹត្តិការណ៍បាញ់ប្រហារពីទាហានថៃ នៅភូមិព្រៃចាន់ ដែលកំពុងព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត នាល្ងាចថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥។

❈នៅថ្ងៃសុក្រ ទី២៨ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលព្រះពុទ្ធ សាសនាបីប្រទេសកម្ពុជា-ឡាវ-វៀតណាម លើកទី៣ ក្រោមមូលបទ «សុខដុម-នីយកម្មព្រះពុទ្ធសាសនា ដើម្បីសន្តិភាពនិងការអភិវឌ្ឍប្រកបដោយចីរភាព» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិ-សង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

❈នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៥ សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុតព្រះ-ករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីសំពះព្រះខែ និងអកអំបុក នៅព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង។



❈នៅថ្ងៃសុក្រ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញជាកិត្តិយសក្នុងវេទិកាជាតិ ស្តីពី «ស្ត្រីក្នុងភាពជាអ្នកដឹកនាំរបស់ស្ត្រី និងក្មេងស្រី ដើម្បីទាំងអស់គ្នា» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ៕

# ឯកឧត្តម ឡាយ សំកុល អគ្គលេខាធិការព្រឹទ្ធសភាអញ្ជើញសំណេះសំណាល ជាមួយនិវត្តជន និងមន្ត្រីរាជការវ័យចំណាស់ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



ឯកឧត្តម ឡាយ សំកុល អគ្គលេខាធិការព្រឹទ្ធសភា

នាព្រឹកថ្ងៃចន្ទ ទី៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយនិវត្តជន និងមន្ត្រីរាជការវ័យចំណាស់ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង នៃវិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និវត្តជន និងមន្ត្រីរាជការវ័យចំណាស់សរុបចំនួន១៨៧នាក់។

ពិធីដ៏មហោឡារិកនេះប្រព្រឹត្តទៅស្របតាមសារាចររបស់រាជរដ្ឋាភិបាលកម្ពុជាលេខ១៦ សរ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៥ និងគោលនយោបាយជាតិស្តីពី មនុស្សវ័យចាស់ នៃព្រះរាជាណាចក្រកម្ពុជា (២០១៧-២០៣០) ដែលបានដាក់ចេញឱ្យក្រសួង ស្ថាប័ន រៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិលើកទី២៧ (១ តុលា ២០២៥) ក្រោមប្រធានបទ«វ័យចាស់ដោយសេចក្តីថ្លៃថ្នូរ»។

ក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការ** បានជម្រាបជូននូវប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខនិងក្តីនឹករលឹកបំផុតរបស់ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ឯកឧត្តមអនុប្រធានទី១** និង**ឯកឧត្តមបណ្ឌិតអនុប្រធានទី២ព្រឹទ្ធសភា** ជូនចំពោះនិវត្តជន មន្ត្រីរាជការទាំងអស់ ក៏ដូចជាប្រជាពលរដ្ឋកម្ពុជានៅទូទាំងប្រទេស។

**ឯកឧត្តមអគ្គលេខាធិការ** បានជម្រាបអំពីការយកចិត្តទុកដាក់របស់**សម្តេចតេជោ** និង**សម្តេចធិបតី** ដោយផ្តោតជាសំខាន់លើការងារមនុស្សចាស់ ដែលជាអាទិភាពមួយក្នុងចំណោមគោលនយោបាយអាទិភាពនានា ហើយនាពេលថ្មីៗនេះ **សម្តេចតេជោ** ក្នុងនាមជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា បានដឹកនាំមហាសន្និបាតវិសាមញ្ញតំណាងសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេស ដោយបានសម្រេចអនុម័តលក្ខន្តិកៈថ្មីរបស់សមាគម និងសេចក្តីសម្រេចកែឈ្មោះរបស់សមាគមពី «សមាគមអតីតយុទ្ធជនកម្ពុជា» ទៅជា «សមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជា»។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក៏បានកសាងលិខិតបទដ្ឋានគតិយុត្តជាច្រើនរួមមាន សេចក្តីសម្រេចការបង្កើតបេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ, មូលនិធិសង្គមកិច្ច, សមាគមសង្គហៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ និងសេចក្តីសម្រេចស្តីពី ការបន្ថែមប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈរួមទាំងយន្តការនានាផងដែរ។

ក្នុងឱកាសនោះផងដែរ **ឯកឧត្តមអគ្គលេខាធិការ** ក៏បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំព្រឹទ្ធសភានីតិកាលមុនៗ ដែលតែងតែយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្តក្នុងការដឹកនាំព្រឹទ្ធសភាឱ្យមានភាពរីកចម្រើនស្មើមុខស្មើមាត់នៅលើពិភពលោក។





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលជាមួយនិវត្តជន និងមន្ត្រីរាជការវ័យចំណាស់ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*





*ឯកឧត្តម ឡាយ សំកុល ប្រគល់ថវិកាជូនតំណាងមន្ត្រីរាជការរ៉យចំណាស់ និងតំណាងនិវត្តជន*

បន្ថែមពីនេះ **ឯកឧត្តមអគ្គលេខាធិការ** បានគូសបញ្ជាក់អំពីសមិទ្ធផលធំៗជាច្រើន ក្រោមការដឹកនាំប្រកបដោយថាមវន្តរបស់រាជរដ្ឋាភិបាល ដែលសម្រេចបាននូវការកើនឡើងនៃកំណើនសេដ្ឋកិច្ច, ការសម្ពោធដាក់ឱ្យប្រើប្រាស់អាកាសយានដ្ឋានអន្តរជាតិតេជោ, ស្ពានអាកាសមរតកតេជោ (ក្បាលថ្នល់), កំពង់ផែសមុទ្ររាម និងសមិទ្ធផលជាច្រើនទៀត ដែលកំពុងកសាងនិងអភិវឌ្ឍ ដូចជា ព្រែកជីកហ្វូណនតេជោ និងស្ពានឆ្លងកាត់ទន្លេ ហើយជាពិសេសបំផុតនោះ គឺការផ្ទេរអំណាចទៅអ្នកជំនាន់ក្រោយ ដើម្បីធានានូវសុខសន្តិភាព ស្ថិរភាពយូរអង្វែងរបស់ប្រទេសជាតិ ដែលជាការលះបង់ និងគិតគូរខ្ពស់បំផុតរបស់សម្តេចតេជោ **ហ៊ុន សែន**។ ទន្ទឹមនឹងនោះ ឯកឧត្តមក៏បានជម្រាបអំពីសមិទ្ធផល និងស្នាដៃជាច្រើនរបស់ព្រឹទ្ធសភា ក្នុងឆ្នាំ២០២៥ និងការរៀបចំសមាជរដ្ឋសភានិងព្រឹទ្ធសភា។

ជាមួយគ្នានេះ **ឯកឧត្តមអគ្គលេខាធិការ** បានជម្រាបអំពីសភាពការណ៍ថ្មីៗនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ជាពិសេសការលះបង់កម្លាំងកាយ ចិត្ត បូជាសាច់ស្រស់ ឈាមស្រស់របស់វីរយុទ្ធជនយើង និងចូលរួមគោរពវិញ្ញាណក្ខន្ធដល់វីរយុទ្ធជន ដែលបានពលីជីវិត ដើម្បីបុព្វហេតុជាតិមាតុភូមិ ពីការឈ្លានពានរបស់ប្រទេសថៃ ព្រមទាំងការលះបង់ដោយមិនខ្លាចនឿយហត់របស់**សម្តេចតេជោ** ក្នុងការចូលរួមប្រឹក្សាយោបល់ជាមួយរាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាព្រំដែន ប្រកបដោយភាពអត់ធ្មត់ខ្ពស់ ក្រោមយុទ្ធសាស្ត្រដោះស្រាយបញ្ហាដោយត្រជាក់ «ស្ងាត់តែមិនស្ងៀម» រហូតឈានដល់ការចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួម រវាង**សម្តេចធិបតី**និង**នាយករដ្ឋមន្ត្រីថៃ** ក្រោមសក្ខីភាពរបស់ឯកឧត្តម **ដូណាល់ ត្រាំ** ប្រធានាធិបតីសហរដ្ឋអាម៉េរិក និងឯកឧត្តម **អាន់វ៉ា អ៊ីប្រាហ៊ីម** នាយករដ្ឋមន្ត្រីម៉ាឡេស៊ី និងជាប្រធានប្តូរវេនអាស៊ាន។

ជាមួយនឹងសមិទ្ធផលដែលព្រឹទ្ធសភាសម្រេចបាននាពេលកន្លងទៅនិងក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតខ្ពស់របស់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានីតិកាលទី៥ **ឯកឧត្តមអគ្គលេខាធិការ**បានគូសបញ្ជាក់ថា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភានឹងបន្តខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួន ដើម្បីរួមចំណែកដល់ដំណើរការលទ្ធិប្រជាធិបតេយ្យ ការកសាង អភិវឌ្ឍន៍ និងបន្តផ្តល់សេវាដល់មុខងាររបស់ព្រឹទ្ធសភា។ ឯកឧត្តមបានថ្លែងអំណរគុណដល់និវត្តជន និងមន្ត្រីរាជការរ៉យចំណាស់ ព្រមទាំងមន្ត្រីរាជការទាំងអស់ ដែលបានរួមចំណែកយ៉ាងសកម្មបំពេញការងារលើគ្រប់វិស័យ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់និងអស់ពីកម្លាំងកាយចិត្ត ដើម្បីបុព្វហេតុជាតិមាតុភូមិ៕





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល និងថតរូបអនុស្សាវរីយ៍ជាមួយនិវត្តជន និងមន្ត្រីរាជការរ៉យចំណាស់ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម ឡាយ សំកុល អគ្គលេខាធិការព្រឹទ្ធសភា អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងកំណត់ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២៥



*ឯកឧត្តម ឡោក ឆាយ* *ឯកឧត្តម ឡាយ សំកុល* *ឯកឧត្តម ខេង សិទ្ធិគុណា* *ឯកឧត្តម អោក បូរ៉ា*

នារសៀលថ្ងៃចន្ទ ទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែតុលា និងកំណត់ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីប្រធាននាយកដ្ឋានឡើង។

មុនចាប់ផ្តើមអង្គប្រជុំ ក្នុងនាមមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា **ឯកឧត្តមអគ្គលេខាធិការ** បានសម្តែងនូវការចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសព លោក **យឿន យ៉ា** អនុប្រធានការិយាល័យ នៃនៃក្រុមជំនួយការអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងកុមារា **យិន ធនិន** ត្រូវជាកូនប្រុសបង្កើត ដែលបានទទួលមរណភាពដោយគ្រោះថ្នាក់ចរាចរណ៍។

មានប្រសាសន៍បន្ថែមពីលើលទ្ធផលនិងទិសដៅការងារ ដែលបានចាក់បញ្ចាំងក្នុងវីដេអូបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តមអគ្គលេខាធិការ**បានណែនាំជូនអង្គប្រជុំបានស្គាល់ លោក **ឌីន សាំទិបុល** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពិធីការនិងទំនាក់ទំនងអន្តរជាតិ ព្រមទាំងបានជម្រាបអំពីការផ្លាស់ប្តូរសមាសភាពអ្នកបកប្រែភាសាបរទេសសម្រាប់សម្តេចតេជោ **ហ៊ុន សែន** ក្នុងជំនួបជាមួយជាមួយភ្ញៀវអន្តរជាតិ។ ចំពោះ





*ទិដ្ឋភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងកំណត់ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២៥*

មុខងារនីតិកម្ម ឯកឧត្តមបានណែនាំដល់អង្គភាពពាក់ព័ន្ធត្រៀមផ្តល់សេវាចំពោះការរៀបចំកិច្ចប្រជុំនានារបស់ព្រឹទ្ធសភា ដើម្បីពិនិត្យហើយឱ្យយោបល់សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ និង សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ ព្រមទាំងសេចក្តីព្រាងច្បាប់មួយចំនួនទៀត ដែលរដ្ឋសភា នឹងបញ្ជូនមក ដែលជាសមត្ថកិច្ចរបស់គណៈកម្មការទី២និងគណៈកម្មការទី៥ព្រឹទ្ធសភា។ ដោយឡែកចំពោះការរៀបចំ របាយការណ៍ចន្លោះសម័យប្រជុំនាពេលខាងមុខ ឯកឧត្តមបានណែនាំដល់ក្រុមការងារ គួរកាត់បន្ថយ ឬសង្ខេបខ្លឹមសារ ឱ្យខ្លីជាងមុន ដោយជៀសវាងកុំឱ្យបាត់បង់ព័ត៌មាន ឬសកម្មភាពរបស់គណៈកម្មការ។ សម្រាប់មុខងារសហប្រតិបត្តិការ អន្តរជាតិ អគ្គលេខាធិការដ្ឋានបាននិងកំពុងរៀបចំដំណើរទស្សនកិច្ចរបស់សម្តេចតេជោ **ហ៊ុន សែន** ទៅកាន់ប្រទេស ម៉ាឡេស៊ី និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅដើមខែធ្នូ ឆ្នាំ២០២៥ ដើម្បីពិភាក្សាការងារ និងចូលរួម អបអរសាទររំលឹកខួបលើកទី៥០ នៃទិវាបុណ្យឯករាជ្យជាតិ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

ចំពោះមុខងារអភិវឌ្ឍន៍ស្ថាប័ន **ឯកឧត្តមអគ្គលេខាធិការ** បានជម្រាបថា ឯកឧត្តមគ្រោងនឹងអញ្ជើញទៅចូលរួម វេទិកាកិច្ចសហប្រតិបត្តិការច្បាប់ចិន-អាស៊ាន លើកទី៧ នៅចុងខែវិច្ឆិកា ឆ្នាំ២០២៥ នៅប្រទេសចិននិងមានការ ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា ជាមួយនឹងមជ្ឈមណ្ឌល ស្រាវជ្រាវច្បាប់ចិន-អាស៊ាន នៃសាធារណរដ្ឋប្រជាមានិតចិន។ ចំណែកឯការសាងសង់អគារថ្មីនៃព្រឹទ្ធសភា **ឯកឧត្តម អគ្គលេខាធិការ** បានណែនាំដល់អង្គភាពពាក់ព័ន្ធជួយតាមដាននិងពន្លឿនការសាងសង់ឱ្យបានរួចរាល់ទាន់ពេលវេលា។ ចំពោះការប្រើប្រាស់ឈ្មោះថ្មីសម្រាប់អគារនិងសាលប្រជុំនានារបស់ព្រឹទ្ធសភា សូមប្រើប្រាស់ឈ្មោះចាស់សិន ដោយ រង់ចាំការសាងសង់អគារថ្មី នៃព្រឹទ្ធសភាឱ្យបានរួចរាល់ និងសម្ពោធហើយសិន។

ជាទីបញ្ចប់ **ឯកឧត្តមអគ្គលេខាធិការ** បានថ្លែងអំណរគុណនិងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំនិងមន្ត្រីរាជការ ទាំងអស់ ដែលបានខិតខំយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាជូនព្រឹទ្ធសភា ដោយទទួលបានលទ្ធផលសំខាន់ៗ ជាច្រើន ដែលជាផលប្រយោជន៍សម្រាប់ព្រឹទ្ធសភានិងប្រជាជាតិ៕



*ទិដ្ឋភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងកំណត់ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២៥*

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម ឡាយ សំកុល អញ្ជើញចូលរួមពិធីបើកវេទិកាកិច្ចសហប្រតិបត្តិការច្បាប់ ចិន-អាស៊ាន លើកទី៧ នៅទីក្រុងឆុងឈីង សាធារណរដ្ឋប្រជាមានិតចិន





*ឯកឧត្តម ឡាយ សំកុល អញ្ជើញមានប្រសាសន៍ក្នុងវេទិកាកិច្ចសហប្រតិបត្តិការច្បាប់ចិន-អាស៊ាន លើកទី៧*

នាព្រឹកថ្ងៃសុក្រ ទី២១ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមកម្មវិធីបើកវេទិកាកិច្ចសហប្រតិបត្តិការច្បាប់ចិន-អាស៊ាន លើកទី៧ រៀបចំដោយសមាគមច្បាប់ចិន ក្រោមអធិបតីភាពរបស់ ឯកឧត្តម **ឆិន ទិនឈីង** (Chen Wenqing) សមាជិកការិយាល័យនយោបាយ នៃគណៈកម្មាធិការកណ្តាលគណបក្សកុម្មុយនីស្តចិននិងជាប្រធានសមាគមច្បាប់ចិន និងឯកឧត្តម **យាន ជាជុន** (YuanJiajun) សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការកណ្តាលគណបក្សកុម្មុយនីស្តចិននិងជាអគ្គលេខាធិការគណៈកម្មាធិការបក្សកុម្មុយនីស្តចិនប្រចាំទីក្រុងឆុងឈីង នៅទីក្រុងឆុងឈីង សាធារណរដ្ឋប្រជាមានិតចិន។

ក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការ** បានអញ្ជើញឡើងថ្លែងសារលិខិតអបអរសាទររបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជូនចំពោះឯកឧត្តម **ឆិន ទិនឈីង** ក្នុងកម្មវិធីបើកវេទិកាខាងលើ ដោយមានការចូលរួមពីគណៈប្រតិភូមកពី១៣ប្រទេសនិងអ្នកចូលរួមជាង៤០០នាក់។

**ឯកឧត្តមអគ្គលេខាធិការ** ក៏បានអញ្ជើញចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន ដែលជាការចាប់ផ្តើមដំបូងនៃកិច្ចសហប្រតិបត្តិការលើវិស័យច្បាប់ដែលជាប្រយោជន៍រួមរវាងស្ថាប័នទាំងពីរ។



*ពិធីថតរូបអនុស្សាវរីយ៍ក្នុងកម្មវិធីបើកវេទិកាកិច្ចសហប្រតិបត្តិការច្បាប់ចិន-អាស៊ាន លើកទី៧*

ប្រភព៖ ខុទ្ទកាល័យឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា

# ឯកឧត្តម ឡាយ សំកុល អញ្ជើញជួបពិភាក្សាការងារជាមួយអគ្គលេខាធិការនៃមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន នៅទីក្រុងឆុងឈីង សាធារណរដ្ឋប្រជាមានិតចិន

ក្នុងឱកាសអញ្ជើញចូលរួមវេទិកាកិច្ចសហប្រតិបត្តិការច្បាប់ចិន-អាស៊ាន លើកទី៧ នៅទីក្រុងឆុងឈីង សាធារណរដ្ឋប្រជាមានិតចិន នៅព្រឹកថ្ងៃសៅរ៍ ទី២២ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងឯកឧត្តម **យស សុខេមរៈ** ប្រធានពិធីការសម្តេចអគ្គមហាសេនាបតីតេជោ ប្រធានព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយលោកសាស្ត្រាចារ្យ Zhang Xiaojun អគ្គលេខាធិការនៃមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន (China-ASEAN Law Research Center—CALRC) និងជាសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រនយោបាយ និងនីតិសាស្ត្រ (Southwest University of Political Science and Law) ។



*ឯកឧត្តម ឡាយ សំកុល ជួបពិភាក្សាការងារជាមួយអគ្គលេខាធិការនៃមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន*

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមអគ្គលេខាធិការ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសមាគមច្បាប់ចិននិងមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន ដែលបានផ្តល់នូវបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ ជូនដល់គណៈប្រតិភូកម្ពុជា ដែលបានចូលរួមក្នុងវេទិកាខាងលើ។

ជាមួយគ្នានេះ **ឯកឧត្តមអគ្គលេខាធិការ** បានប្រគល់ជូននូវលិខិតអបអរសាទររបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជូនចំពោះសមាគមច្បាប់ចិននិងមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន ក្នុងការរៀបចំវេទិកាកិច្ចសហប្រតិបត្តិការច្បាប់ចិន-អាស៊ាន លើកទី៧ ប្រកបដោយជោគជ័យនិងទទួលបានលទ្ធផលជាផ្លែផ្កា ជាពិសេសទទួលបាននូវការចូលរួមពីអ្នកជំនាញនិងមានបទពិសោធខាងវិស័យច្បាប់មកពី ១៣ប្រទេស រួមមានៈបណ្តាប្រទេសក្នុងតំបន់អាស៊ាន ដែលសបញ្ជាក់នូវកិច្ចខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលក្នុងការកសាងបាននូវកិច្ចសហប្រតិបត្តិការដ៏ល្អ និងការអភិវឌ្ឍបង្កើនធនធានមនុស្សជំនាញក្នុងវិស័យច្បាប់យ៉ាងទូលំទូលាយ។

ក្នុងជំនួបពិភាក្សានោះផងដែរ **ឯកឧត្តមអគ្គលេខាធិការ** បានគូសបញ្ជាក់នូវសារៈសំខាន់នៃការចាប់ផ្តើមសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន តាមរយៈការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី ការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យច្បាប់ ការបណ្តុះបណ្តាលមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីផ្លាស់ប្តូរនូវបទពិសោធ និងលើកកម្ពស់កិច្ចការងារស្រាវជ្រាវរវាងស្ថាប័នទាំងពីរ។

ជាចុងក្រោយ **ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ឯកឧត្តមប្រធានពិធីការសម្តេចតេជោ**និងគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញទស្សនាមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន និងសាកលវិទ្យាល័យវិទ្យាសាស្ត្រនយោបាយនិងនីតិសាស្ត្រ។




*ឯកឧត្តម ឡាយ សំកុល ប្រគល់ជូននូវលិខិតរបស់ សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ជូនចំពោះសមាគមច្បាប់ចិននិងមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន*



*ឯកឧត្តម ឡាយ សំកុល អញ្ជើញទស្សនាមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន*

ប្រភពៈ ខុទ្ទកាល័យឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



❈នាព្រឹកថ្ងៃចន្ទ ទី២៧ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីក្រុងពាលីបើកការដ្ឋានសាងសង់ប្រព័ន្ធរំដោះទឹកក្នុងបរិវេណព្រឹទ្ធសភា ដែលជាជំនួយគាំទ្រពីសាលារាជធានីភ្នំពេញ នៅវិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃអង្គារ ទី២៨ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំស្តីពីការរៀបចំសិក្ខាសាលាស្តីពីបញ្ញាសិប្បនិម្មិត (AI) និងកិច្ចការពាក់ព័ន្ធផ្សេងៗមួយចំនួនទៀត ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃសុក្រ ទី៣១ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា រួមជាមួយឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** នាយកខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា និងឯកឧត្តម **យស សុខេមរៈ** ប្រធានពិធីការសម្តេចតេជោប្រធានព្រឹទ្ធសភា បានអញ្ជើញសួរសុខទុក្ខ ឯកឧត្តម **ម៉ុន សំបូរ** ដែលបំពេញការងារនៅខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភានិងជារដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី កំពុងសម្រាកនិងព្យាបាលជំងឺនៅមន្ទីរពេទ្យកាល់ម៉ែត។



❈នាព្រឹកថ្ងៃសុក្រ ទី៣១ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា អមដោយឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា, ឯកឧត្តម **យស សុខេមរៈ** ប្រធានពិធីការសម្តេចតេជោប្រធានព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញគោរពជូនពរឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ក្នុងឱកាសពិធីចម្រើនជន្មាយុរបស់ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា នៅបន្ទប់ប្រជុំឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា។

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

❈នារសៀលថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោក **យឿន យ៉ា** ជំនួយការអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅភូមិស្វាយឫស្សី សង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ។



❈នាព្រឹកថ្ងៃសុក្រ ទី៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបជាមួយក្រុមការងារ ដឹកនាំដោយ ឯកឧត្តម **អ៊ឹម សុខរិទ្ធី** ទីប្រឹក្សាបច្ចេកទេសនៃក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គម និងវប្បធម៌ នៃទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាអំពីការរៀបចំចងក្រងសៀវភៅ «វិមានសាមគ្គីភាព អគារកេរដំណែល និងប្រវត្តិសាស្ត្រ» នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។



❈នារសៀលថ្ងៃសុក្រ ទី៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យបច្ចុប្បន្នភាពគេហទំព័រព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រុមការងារបច្ចេកទេស នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃពុធ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំដំបូង នៃក្រុមការងារស្រាវជ្រាវ និងវិភាគព្រឹត្តិការណ៍តំបន់ និងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

❉នារសៀលថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម បណ្ឌិត **ឈីវ យីស៊ាន** នាយកខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារសំខាន់ៗក្នុងរយៈពេល៣ខែ ព្រមទាំងលើកទិសដៅការងារបន្តរបស់ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា នៅសាលពិសេសក្រោម វិមានព្រឹទ្ធសភា។



❉នៅថ្ងៃទី១០ និងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសក-កម្មមនុស្សធម៌នៃប្រទេសបារាំងប្រចាំនៅកម្ពុជា ចុះទៅពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋឥតយកកម្រៃ នៅក្នុងបរិវេណវត្តសូរិយាពោធិ៍មាស ហៅវត្តក្តីចាស់ ស្ថិតក្នុងភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❉នាព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ខួន សុខវេង** អគ្គនាយកពិធីការ និងទំនាក់ទំនងអន្តរជាតិ បានអនុញ្ញាតឱ្យលោក Charles Garrigue ជានិស្សិតឆ្នាំទី២ ផ្នែកវិទ្យាសាស្ត្រនយោបាយ (Sciences Po Aix Aix-en-Provence)និងជាកម្មសិក្សាការីនៅនាយកដ្ឋានកិច្ចការប្រាំងកូហ្វូន នៃអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលជួបសម្តែងការគួរសមនិងជម្រាបលា នៅបន្ទប់ឯកឧត្តមអគ្គនាយក។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ
ទូរសព្ទ៖ (855) 23 211 441, 211 442, 211 443 ទូរសារ៖ (855) 23 211 446
E-mail: secretariat@senate.gov.kh
www.senate.gov.kh www.elibrary.senate.gov.kh
senate of cambodia